# វចនាធិប្បាយ

ភាគទី ៤

អធិប្បាយពាក្យវប្បធម៌

គឺ:

បណ្ឌិត ឈឹម - ទូប

រៀបរៀង

ឧបត្ថម្ភការសិក្សាផ្នែកអក្សរសាស្ត្រខ្មែរ

★

ការផ្សាយរបស់

ខេមរវិទ្យា លេខ១៨

វិថីព្រះបាទនរោត្តម ភ្នំពេញ ខាងអគ្នេយ៍វត្តលង្កា

ព. ស. ២៤៩៩ គ. ស. ១៩៥៧

# វចនាធិប្បាយ

ភាគទី ៤

អធិប្បាយពាក្យវប្បធម៌


គឺ:

បណ្ឌិត ឈឹម - ទូប


រៀបរៀង

ឧបត្ថម្ភការសិក្សាផ្នែកអក្សរសាស្ត្រខ្មែរ

★


ការផ្សាយរបស់

បណ្ណាគារ **ខេមរវិទ្យា** លេ១៨

វិថីព្រះបាទនរោត្តម ភ្នំពេញ ខាងអគ្នេយ៍វត្តលង្កា

ព. ស. ២៤៩៩ គ. ស. ១៩៥៧

# សន្លឹកប្រាប់ពាក្យខុសត្រូវ

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| ២ | ១ | គ | ឃ |
| ២ | ១ | ប | ឞ |
| ២ | ៣ | គ | ឝ |
| ៣ | ១១ | [illegible] | [illegible] |
| ១២ | ១០ | —ហា—រ៉ី—ម៉ | —ហា—រុ៉ី—ម:— |
| ១៦ | ២ | Obligtons . . . | Obligations . . . |
| ១៦ | ១២ | សញ្ញាប័ត្រ | សញ្ញាបត្រ |
| ២៨ | ៧ | prévoyance | Prévoyance |
| ៣០ | ១២ | សម្រែក | សម្រែក |
| ៥២ | ២ | សកាន | កាសន |
| ៥៩ | ៦ | ន.សំ. | ន.( សំ. |
| ៧២ | ១២ | ធ្វ៊ី | ធ្វើ |
| ៧៣ | ១ | Puplic | Publique |
| ៧៣ | ៨ | Répuplique | République |

លេខកត :
លេខបញ្ជី :

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| ៩២ | ៨ | Aete | Acte |
| ៩៨ | ១០ | អ្នប្រព្រឹត្តល្អ | អ្នកប្រព្រឹត្តល្អ |
| ៩៩ | ១ | Constructoin | Construction |
| ៩៩ | ៣ | ស្ថានបទ័ | ស្ថាបទ័ |
| ១០០ | ៧ | Arttste | Art |
| ១០៧ | ១០ | ផាស៊ី | ភាស៊ី |
| ១០៧ | ១៤ | សជុីវភាព | សុជីវភាព |
| ១១៦ | ១០ | ចណាយ | ចំណាយ |

---

# សូមអភ័យទោស

ដោយរោងពុម្ពពុំមានអក្សរគ្រប់គ្រាន់ចំពោះភាសាសំស្ក្រឹត ត្រង់កន្លែងខ្លះ , ដូចនេះរោងពុម្ពបានប្រើអក្សរ :—

| | | |
|---|---|---|
| គ | ជំនួស | ឝ |
| គា | " | ឝា |
| ប | " | ឞ |
| ធា | " | ឞា |

\+ + +

## ស

ស= ព្យញ្ជនៈ ទី៣០ តាមលំដាប់ពួកព្យញ្ជនៈទាំង៣៣ តួ , ជាព្យញ្ជនៈ ទី៥ក្នុងសេសវគ្គ ឬ អវគ្គ សម្រាប់ប្រើក្នុងភាសាមគធៈ និងភាសាខ្មែរ ជាទន្តជៈ មានសំឡេងកើតត្រង់ប្រទល់ធ្មេញ ៗ (Dentales), , ជា អឃោសៈ មានសំឡេងមិនគឹកកង គឺសំឡេងតូច ឬ សំឡេងគ្រលួប (Sourdes), ហើយអាចបញ្ចេញសំឡេងបាន ២ យ៉ាង គឺនៅជា ស ដដែលមួយយ៉ាង, ជា ស៊ មួយយ៉ាង ដោយប្រើត្រីសព្ទឲ្យមានសំឡេងជា ឃោសៈ វិញ ប៉ុន្តែប្រើបានចំពោះតែព្យាង្គទោលដូចពាក្យថា ស៊ី ជាដើម ឬ នៅខាងដើមព្យាង្គឯទៀត ៗ កាលណាបើនៅខាងចុងព្យាង្គដែលមានអក្សរពីរតួរឡើងទៅ មិនបាច់ដាក់ត្រីសព្ទឡើយ អាចបញ្ចេញសំឡេងទៅតាមអក្សរឃោសៈ ឬ អឃោសៈ ដែលនៅខាងដើម ៗ តាមរបៀបព្យញ្ជនៈសម្រាប់ប្រើក្នុងភាសាសំស្ក្រឹតក្នុងសេសវគ្គ

រៀនអក្សរ ឝ (ស–គ) ជាតាលុជៈ ត្រង់ទី៥, ឞ (ស–ប) ជាមុទ្ធជៈ ត្រង់ទី៦, ស (ស–ល) ជាទន្តជៈ ត្រង់ទី ៧ (រៀនជា យ រ ល វ ឝ ឞ ស) ។

ស័ក ( Millésime n.m. ) ( អ. ថ. សាក់ ) ន. ( សំ. គក ) កាល, សម័យ, យុគ, ការរាប់លំដាប់ឆ្នាំ, ពួកជនជាតំណាវង្សដែលជាប់ទាក់ទងដោយក្សត្រិយ៍សកៈ ឬ សាលិវាហនៈ ។

អធិ. ស័កនេះ បានដល់កាលគ្រាសម័យនៃការរាប់ថ្ងៃ–ខែ–ឆ្នាំ, ខ្មែរប្រើពាក្យនេះចំពោះតែការរាប់លំដាប់នៃឆ្នាំតាំងពីស័កទី១ ដល់ស័កទី១០ ត្រឡប់សាមករាប់ពីស័ក ទី ១ វិញ គឺរាប់ថា: ឯកស័ក, ទោស័ក, ត្រីស័ក, ចត្វាស័ក, បញ្ចស័ក, ឆស័ក, សប្តស័ក, អដ្ឋស័ក, នព្វស័ក, សំរឹទ្ធិស័ក, ដូចជា: ឆ្នាំថោះឯកស័ក ។ល។ ឆ្នាំជូតសំរឹទ្ធិស័ក; ឆ្នាំឆ្លូវឯកស័ក, ... ។

ម.ព. សកពជ ផង ។

សកម្ម (Actif) (អ. ថ ស:-ក័ម ) ន. (ម.) អំពើរបស់ខ្លួន;កិច្ចការចំពោះខ្លួន ។

អធិ. សកម្មនេះ < ស « ខ្លួន » + កម្ម « អំពើ, កិច្ចការ, ការងារ » បានដល់កម្មផ្ទាល់ខ្លួន ឬ អំពើដែលជាប់ទាក់ទងដោយខ្លួនឯងគឺអំពើដែលខ្លួនត្រូវធ្វើផ្ទាល់ខ្លួនឯង ។

សកម្មភាព (Activité n.f.) (អ. ថ. ស: - ក័ម - ម: - ភាព) ន. (ម. -ការ) ភាពនៃអំពើរបស់ខ្លួន, ភាពនៃកិច្ចការចំពោះខ្លួន, ការនៃកម្មផ្ទាល់ខ្លួន ។

អធិ. សកម្មភាពនេះ < សកម្ម " អំពើរបស់ខ្លួន, កិច្ចការចំពោះខ្លួន, កម្មផ្ទាល់ខ្លួន » + ភាព " ភា:, បែបបទ, លំនាំ, ឫកពា, ... » បានដល់ភាពនៃអំពើ ឬ ការងារផ្ទាល់ខ្លួន គឺការៈនៃអំពើដែលខ្លួនត្រូវធ្វើត្រូវប្រកបឲ្យកើតឡើងដោយផ្ទាល់ខ្លួនឯង ។

សករាជ (Millésime n.m.) (អ. ថ. ស:- ក:រ៉ាច ឬ ស័ក-ក្រាច) ន. (សំ. ឝក+រាជន៍ ឬ រាជ) កាលរបស់ស្ដេច; សម័យស្ដេច ឬ ស្ដេចសម័យ ។

សករាជនេះ <សក «កាល, សម័យ; យុគ; ការរាប់លំដាប់ឆ្នាំ...» + រាជ «ស្ដេច» បានដល់ការរាប់ថ្ងៃ-ខែ-ឆ្នាំ ឬ ការរាប់ត្រឹមតែឆ្នាំ តាមកាលកំណត់ដែលតាំងទុកពីមួយរៀងមក ដោយមានបុគ្គលអស្ចារ្យ ឬដោយមានហេតុអស្ចារ្យណាមួយ ដែលពួកជនានុជនអ្នកគោរព ត្រូវកត់ត្រាទុកមិនឲ្យបាត់, ត្រូវប្រើក្នុងសំបុត្រចុតហ្មាយជាដើម បន្ថែមមួយលេខរៀងរាល់ឆ្នាំ ។ ពាក្យថា: សករាជ (ឬស័ក) នេះកើតឡើងអំពីជនពួកមួយ ហៅថាពួក តាតិ នៅក្នុងតំបន់មួយ ខាងទិសពាយ័ព្យប្រទេសឥណ្ឌា, កាលពុទ្ធសករាជ ៦២១ ឆ្នាំ, ជនពួកនេះបានលុកលុយចូលមកវាតអំណាចក្នុងប្រទេសឥណ្ឌាប៉ែកខាងលិច បានតាំងក្សត្រិយ៍

ជាតិរបស់ខ្លួន មានព្រះនាមថា សកៈ (គក) ឬ សាលិវាហនៈ (គាលិវ៉ាហន) ក៏តាំងការរាប់ឆ្នាំតាំងពីមួយឡើងមក ហៅរបៀបការរាប់ឆ្នាំនោះថា ស័ក (គ័ក) ឬ សករាជ (គករាជ), ដល់ចំណេរតមក ហៅថា មហាសករាជ ជាប់មានមកក្នុងប្រទេសយើងរៀងដល់សព្វថ្ងៃនេះ ។ ក្នុងព្រះរាជពង្សាវតារ ឬ ប្រវត្តិសាស្ត្រខ្មែរថា ព្រះបាទសម្ដេចព្រះអរិង្គពលពាហនោ (ព្រះកេតុមាលា) បានតាំងមហាសករាជ ១ ក្នុងកាលពុទ្ធសករាជ ៦២១ ព្រះបាទសម្ដេចព្រះសន្ធពអមរិន្ទបរមព្រហ្មកិល (ពញាក្រែក) បានតាំងចុល្លសករាជ ១ ក្នុងកាលពុទ្ធ-សករាជ ១១៨១. (ម.ព. ស័កខាងដើមផង) ។ យ·គ.ប. ។

សក្ខីភាព (Témoignage) (អ.ថ. ស័ក-ខី-ភាប) ន. (ម. សក្ខិភាវ, សំ សក្ស្យ—) ភាពជាសាក្សី, ភាពជាស្ម, បន្ទាល់ ។

គធិ. សក្ខិភាពនេះ < សក្ខិ « សាក្សី, ស្ម, បន្ទាល់ » + ភាព « ភាវៈ, បែបផែន, លំនាំ, ឫកពា, » បានដល់ភាពនៃ

បុគ្គលជាសាក្សី គឺភាពជាស្មអ្នកដឹងឮ ។ ឧទា. សក្ខីភាពនៃសោមនស្ស (Témoignage de satisfaction) ។

សង្កថា (Allocution n.f.) (អ.ថ. ស័ង–ក: –) ន. (សំ. ម. សំកថា) ពាក្យសន្ទនា, ការសន្ទនាគ្នា ។

អធិ. សង្កថានេះ <សំ „ ព្រម, ប្រពៃ ... ” ផ្លាស់ ំ> ង+កថា „ ពាក្យ, សំដី, វាចា ” បានដល់ការសន្ទនាគ្នាទៅវិញទៅមក គឺការបរបាទនិយាយសាកសួរគ្នាទៅវិញទៅមក (ការនិយាយប្រាស្រ័យគ្នា) ។

សង្ខរ័ណ (Infrastructure n.f.) (អ. ថ. ស័ង-ខ:រ៉ុន) ន. (ម. សង្ខរណ ឬ សំខរណ) គ្រឿងប្រកប ឬតាក់តែង; គ្រឿងប្រុង; គ្រឿងប្រមូលផ្តុំ ។

អធិ. សង្ខរ័ណនេះ <សំ „ ព្រម, ប្រពៃ, បរិបូណ៌ ... ” + ខរណ „ ការតាក់តែង, ការប្រុង, ការកសាង ... ” បានដល់គ្រឿងទព្វសម្ភារៈដែលគេប្រកបប្រុង

ប្រៀប ឬ ដែលគេប្រមូលផ្តុំឲ្យកើតឡើងព្រម ។

សង្គម ឬ សង្គ័ម ( Société n.f. ) (អ.ថ .សង់-គំ ឬ ស័ង-គំ ) ន. (សំ. ម. ) ការជួបជុំគ្នា ; ការប្រជុំ-គ្នា ; ការរាប់រកគ្នា ; ការរួបរួមគំនិតគ្នា ; ការចូលហ៊ុន ឬ ចូលសមាគមជាមួយគ្នា ។

សង្គម ឬ សង្គ័មនេះ បានដល់ការរួបរួមគំនិតជាមួយគ្នា ឬ សមាគមរួមកម្លាំងធ្វើការរបរផ្សេងៗ ជាមួយគ្នា , ការនៅក្នុងស្រុកជាមួយគ្នា , ការចូលបក្សពួកជាមួយគ្នា ។ល។ . សង្គមប្រជាធិបតេយ្យ ( Société démocratique) ។

សង្គមកិច្ច ( Action social ) (អ. ថ. ស័ង-គៈ-មៈ-កិច ឬ ស័ង-គំ-មៈ-) ន. (ម.) កិច្ចដែលរួបរួមគំនិតគ្នា ; ការងារដែលគេធ្វើដោយសមាគមគ្នា ។

អធិ. សង្គមកិច្ចនេះ < សង្គម « ការជួបជុំគ្នា , ការរួបរួមគំនិតគ្នា , ការចូលហ៊ុន ឬ ចូលសមាគមគ្នា; ការរួបរួមបង់ចាប់

គ្នា " + កិច្ច " អំពើដែលគេត្រូវធ្វើ , ការងារដែលគេត្រូវធ្វើ " បានដល់កិច្ចដែលត្រូវធ្វើដោយរួបរួមគំនិតចង់ភ្ជាប់ជាមួយគ្នា ឬ ការងាររបស់អ្នកស្រុកដែលចង់ភ្ជាប់សមាគមគ្នាធ្វើអ្វីផ្សេងៗ ។

សង្គមវិជ្ជា ( (Sociologie) ) ( អ. ថ. ស័ង-គៈ-មៈ-វិច-ជា ឬ ស័ង-គំ-មៈ- ) ន. (ម.) ការរួបរួមវិជ្ជា , ការប្រមូលផ្តុំវិជ្ជា ; សមាគមខាងចំណេះវិជ្ជា ។

អធិ. សង្គមវិជ្ជានេះ < សង្គម " ការជួបជុំគ្នា , ការរួបរួមគំនិតគ្នា , ការចូលហ៊ុន ឬ ចូលសមាគមគ្នា ; ការរួបរួមចង់ភ្ជាប់គ្នា .... " + វិជ្ជា " ចំណេះ , ការចេះដឹង ... " បានដល់ការរួបរួមប្រមូលផ្តុំវិជ្ជាផ្សេងៗ ឬ វិជ្ជាដែលគេប្រមូលរួបរួមបញ្ចូលជាមួយផ្សំឲ្យចម្រើនឡើង ។

សង្គមរាស្ត្រនិយម (Socialisme n.m.) ( អ.ថ. ស័ង - គំ - រាស - និ - យំ ឬ សង់-គំ - ) ន. (សំ.

សង្គម + រាស្ត្រ + និយម ; ម. សង្គមរាដ្ឋនិយម) សេចក្ដីកំណត់យកការប្រួបប្រួមគំនិតរាស្ត្រ, ការប្រួបប្រួមចងភ្ជាប់គ្នានៃប្រជាជនដោយកំណត់ ។

អធិ: សង្គមរាស្ត្រនិយមនេះ < សង្គម « ការប្រជុំគ្នា, ការប្រួបប្រួមគំនិតគ្នា, ការចូលហ៊ុន ឬ ចូលសមាគមគ្នា, ការចងភ្ជាប់គ្នា. » + រាស្ត្រ «ប្រជាជន, ប្រជាជនសម្រាប់ដែន, អ្នកនៅក្នុងដែន» + និយម « សេចក្ដីកំណត់, ធម្មតា, ធម្មជាតិ, អនុលោមតាម, ទៀងទាត់» បានដល់ការប្រួបប្រួមគំនិតចងភ្ជាប់គ្នានៃពួកប្រជាជនអ្នកនៅក្នុងដែនទីមួយៗ ដោយកំណត់ឬ ជាឈ្មោះគណៈបក្ស (Pari) មួយហៅថា គណៈបក្សសង្គមរាស្ត្រនិយម ។ អ្នកសង្គមរាស្ត្រនិយម (Socialiste n.m.) ។ ឃ.គ.ប. ។

សង្គមិក (Sociétaire n.m.) (អ.ប.ស័ង–គៈ មិក) ន. (ម.) អ្នកចូលសង្គម; អ្នកចូលហ៊ុនឬចូលសមាគម, អ្នក

ចូលរួបរួមគំនិតជាមួយគ្នា ។

អធិ: សង្គមិកនេះ បានដល់អ្នកចូលសង្គម ឬ អ្នកចូលសមាគម គឺអ្នកដែលចូលរួបរួមគំនិតបង្កាប់គ្នាជាពួកព័ត្តដើម្បីធ្វើការរបរអ្វីមួយ

សង្គមិកសមាជិក (Membre sociétaire) (អ. ឋ. សង័–គៈ–មិ–កៈ–សៈ–មា–ជិក ឬ សង័– គៈ– មិក –សៈ–មា– ) ន. (ម.) សមាជិកអ្នកប្រកបដោយការរួបរួមសមាជិកសម្រាប់សង្គម ។

អធិ. សង្គមិកសមាជិកនេះ‹សង្គមិក «អ្នកចូលសមាគម; អ្នកចូលសង្គម ; អ្នកប្រកបដោយការរាប់អានគ្នា ...» + សមាជិក « អ្នកដែលមានអំណាចត្រូវចូលកាន់ទីប្រជុំបាន ; អ្នកបង្កើតសមាជ » បានដល់សមាជិកជាអ្នករួបរួមសង្គមគ្នា ឬ សមាជិកដែលប្រកបដោយការនៅក្នុងសង្គម ។

សង្គហបទ (Chrestomathie) (អ. ឋ. សុន៍ ឬ

ស័ង-គៈ-ហៈ-ប៉ត់) ន. (ម.; សំ. សំគ្រហបទ) បទសង្គ្រោះ; ចំណែកនៃការសង្គ្រោះ ឬ ស្រោចស្រង់ ។

អធិ. សង្គហបទនេះ ‹ សង្គហ «សេចក្ដី ឬការសង្គ្រោះ; ការកាន់យក ឬ ស្រង់, សេចក្ដីយកដោយសង្ខេប» + បទ «ឧបាយ; ហេតុ; ចំណែក; ផ្លូវ; ដើង; ទំនង, ដំណើរ ទំនង, ដើមទង» បានដល់បទសង្គ្រោះ គឺចំណែកនៃការ សង្គ្រោះ ឬដំណើរទំនងនៃសេចក្ដីស្រោចស្រង់ ។

សង្គ្រាម (Guerre n.f.) (អ. ថ. ស័ង-គ្រាម) ន. (សំ. ម. សង្គាម) ចម្បាំង, ទ័ព, សឹក, ។

អធិ. សង្គ្រាមនេះ បានដល់ចម្បាំង គឺការកើតកលិយុគ ច្បាំងកាប់ចាក់បាញ់សម្លាប់គ្នាទៅវិញទៅមក ឧទា. សង្គ្រាម គ្នាឯង ឬចម្បាំងគ្នាឯង (Guerre civile ou intestine) ។

សង្ឃដ (Conflit n.m.) (អ. ថ. ស័ង-ឃ័ត) ន. (ម. សង្ឃដ) ជម្លោះ; ការទាស់ទែង, ការប៉ះទង្គិច ។

អធិ. សង្ឃជ័នេះ បានដល់ការឈ្លោះតាសំខែនគ្នា ឬការប៉ះទង្គិចគ្នា ។

សង្ហារិម ( Mobilier n.m.) (អ . ប . សង់ហា - រ៉ុ.មៈ ឬ – រិម ) ន . ( ម . ) របស់ដែលកម្រើកបាន; វត្ថុដែលនាំ ឬ លើកយកទៅមកបាន ។

អធិ. សង្ហារិមនេះ បានដល់របស់ ឬ វត្ថុដែលនាំយក ឬ លើកយកទៅមកបាន , ដែលអាចធ្វើឲ្យកម្រើក ឬ ឲ្យឃ្លាតចាកទីបាន ។ ព . ផ្ទុ. អសង្ហារិម ( Immobilier ) ។

សង្ហារិមទ្រព្យ ( Biens mobiliers) ( អ . ប . សង់ ឬ ស័ង -ហា - រ៉ុ- មៈ – ទ្រាប់ ) ន . (សំ. សង្ហារិម–ទ្រវ្យ ; ម . សង្ហារិមទព្វ ) ទ្រព្យដែលកម្រើកបាន ; ទ្រព្យដែលនាំយកទៅមកបាន ។

អធិ. សង្ហារិមទ្រព្យនេះ « សង្ហារិម » ដែលនាំយក ឬ ដែលលើកយកទៅមកបាន, ដែលអាចធ្វើឲ្យកម្រើក

ឬ ឃ្លាតចាកទីបាន" + ទ្រព្យ "វត្ថុ, ធនធាន, សម្បត្តិ" បានដល់ទ្រព្យដែលអាចកម្រើកបាន ឬ ដែលអាចនាំយកទៅមកបាន ដូចជា: គោ ក្របី មាស ប្រាក់ជាដើម ។ ព. ផ្ទ. អសង្ហារិមទ្រព្យ (Biens immobiliers) ។

សច្ច ឬ សច្ចៈ (Vérité n.f.) (អ. ថ. សច់-ចៈ) ន.(ម.; សំ. សត្យ) សេចក្ដីពិត; ដំណើរត្រឹមទៀង; ទៀងទាត់ ; ដំណើរទៀងត្រង់ ។

អធិ. សច្ច ឬ សច្ចៈនេះ សំដៅយកសេចក្ដីពិតត្រង់ត្រូវ ឬ ពាក្យនិយាយទៀងទាត់ ប្រាកដប្រជា មិនល្អៀងឃ្លៀងឃ្លាត ដែលហៅថាពាក្យសត្យ ។ ព. ផ្ទ. អសច្ច ឬ មុសាវាទ ។

សច្ចានុម័តិ ឬ សច្ចាប័ន (Ratification n.f.) (អ.ថ. សច់-ចា-នុ-ម័ត - បាន់) ន.(ម. សច្ចានុមតិ ឬ សច្ចាបន) ការធ្វើសេចក្ដីពិត ; ការយល់

ព្រមដោយទៀងត្រង់ ។

អធិ. សច្ចានុម័ត ឬ សច្ចាប័ននេះ បានដល់ការយល់-ព្រមដោយត្រង់ប្រាកដប្រជា ឬ ការធ្វើឲ្យទៀងទាត់ប្រាកដប្រជា គឺការយល់ព្រម ឬ ការឲ្យយោបល់ដោយស្របគំនិតជាមួយគ្នា ទៀងទាត់ប្រាកដប្រជា ។ ឲ្យសច្ចានុម័ត ឬ ឲ្យសច្ចាប័ន (Ratifier) ។

សជ្ឈត្តិកៈ (Intrinsèque adj.) (អ.ប. ស័ច-ឈ័ន-តិ-កៈ) គុ. (ម.) ដែលប្រកបដោយប្រាកដខាងក្នុង ; ដែលប្រកបដោយវត្ថុមានតម្លៃនៅខាងក្នុង ។

អធិ. សជ្ឈត្តិកៈនេះ (សជ្ឈ « ប្រាកដ . . . » + អត្តិកៈ ដែលមានក្នុងទីបំផុត , ដែលមាននៅខាងចុងបង្អស់ . . . » «បានដល់វត្ថុដែលមានតម្លៃនៅខាងក្នុង ដូចជាដុំថ្មដែលមានត្បូងយ៉ាងល្អនៅខាងក្នុង ។

សញ្ជាតិ (Nationalité n.f.) (អ.ប. ស័ញ-

ជាត ) ន. ( ម. ) ការកើតឯង , ការដុះឯង , ការកើតតាមធម្មតា ។

អធិ. សញ្ជាតិនេះ បានដល់កំណើតរបស់ខ្លួន គឺជាតិនៃមនុស្សគ្រប់សាសន៍ ឧទា.មនុស្សនេះមានសញ្ជាតិជាចិន, –ជាយួន , – ជាខ្មែរ ។

សញ្ញា (Marque n.f.) ( អ.ថ.ស័ញញ៉ា ) ន. ( ម. ) សេចក្ដីសំគាល់ : ការចំណាំ , ការចង់ចាំបាន ។

អធិ. សញ្ញានេះ សំដៅយករូប យីហោ ត្រា ជាគ្រឿងសំគាល់ ឬ ជាគ្រឿងសំរាប់ចំណាំ ។

សញ្ញាណ (Notion n.f.) ( អ . ថ. ស័ញ–ញ៉ាន ) ន. ( ម. , សំ . សំជ្ញាន) សេចក្ដីដឹងជាក់ , ការយល់ច្បាស់, សេចក្ដីចូលចិត្តស៊ប់ ។

អធិ. សញ្ញាណនេះ បានដល់អ្វី ៗ ដែលប្រើជាគ្រឿងសំគាល់កិច្ចការនីមួយ ៗ ឲ្យដឹងជាក់លាក់ ឬ វត្ថុជាគ្រឿង

សំគាល់ ( យ៉ំហោ ) ។

សញ្ញាប័ណ្ណនាមនិទ្ទេស (Obligatons nominatives) ( អ.ប. ស័ញ – ញ៉ា – ប័ន – នា – មៈ – និត – ទេស ) ន. ( ម. សញ្ញាបណ្ណនាមនិទ្ទេស ) សំបុត្រសំគាល់ការសំដែងចេញឈ្មោះ ; ប័ណ្ណ ចំណាំការហៅឈ្មោះ ។

អធិ. សញ្ញាប័ណ្ណនាមនិទ្ទេសនេះ < សញ្ញា «គ្រឿងសំគាល់, ចំណាំ» + បណ្ណ « សំបុត្រ; ក្រដាស; លិខិត» + នាម » ឈ្មោះ» + និទ្ទេស ការសំដែងចេញ, ការពោលចេញ» បានដល់ក្រដាស ឬ សំបុត្រសំគាល់ការសំដែងចេញនូវឈ្មោះ ។

សញ្ញាប័ត្រ (Diplôme )(អ.ប. ស័ញ–ញ៉ា-ប័ត្រ) ន. ( ម. សញ្ញាប័ត្ត; សំ. សំជ្ញាបត្រ) សំបុត្រសម្រាប់សំគាល់; សំបុត្រកំណត់ហេតុជាគ្រឿងចំណាំ ។

អធិ. សញ្ញាប័ត្រនេះ < សញ្ញា " គ្រឿងសំគាល់,.. " + បត្រ "សំបុត្រ, ក្រដាសលិខិត" បានដល់លិខិតកំណត់ហេតុសំគាល់បំណោះវិជ្ជាចេញជាត្រាតាំងឲ្យជាកស្តុតាងដល់អ្នករៀនដែលប្រឡងជាប់ មានអំណាចត្រូវទទួលយកតាមលក្ខណបញ្ញត្តិ

ឧទា. សញ្ញាប័ត្រចេញពីសាលាសិក្សាអនុវត្តន៍ជាន់ខ្ពស់សម្រាប់បព្វជិត(Diplôme de sortie de l'Ecole supérieure d'application des bonzes) ។ សញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់ខាងគរុវិជ្ជាខ្មែរ (Diplôme d'Etudes primaires supérieures Normales Cambodgiennes) ។ សញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់បារាំងជាតិសាយ (Diplôme d'Etudes primaires supérieures Franco-Indigènes) ។ សញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់ឥណ្ឌូចិន ( Diplôme d'Etudes primaires supérieures Indochinoises) ។ សញ្ញាប័ត្រមធ្យមសិក្សាបារាំងខ្មែរ ( Diplôme

d'Etudes secondaires Franco. Khmères) ។ សញ្ញាប័ត្រសម្រាប់រដ្ឋ ឬ រដ្ឋសញ្ញាប័ត្រ (Diplôme d'Etat) ។ សញ្ញាប័ត្រវិជ្ជាបានបង្រៀនយុត្តិធម្មសាស្ត្រនិងសេដ្ឋសាស្ត្រជាតិ (Diplôme de l'Institut National d'Etudes Juridiques et Economiques) ។ សញ្ញាប័ត្រសាលាគរុវិជ្ជាជាន់ខ្ពស់នៃមហាវិទ្យាល័យនៅហាណូយ (Diplôme d'Etudes primaires pédagogiques de l'Université d'Hanoï) ។ល។

សណ្ឋាគារ (Hôtel n. m.) (អ. ប. -សន់-ឋាគា) ន. (ម; សំ. សំស្ថាគារ) ផ្ទះសំណាក់, មន្ទីរសម្រាប់ទទួលភ្ញៀវ, ផ្ទះសំណាក់របស់រាជការសម្រាប់ភ្ញៀវមកពីចម្ងាយៗ

អធិ. សណ្ឋាគារនេះ ប៉ានដល់ផ្ទះសំណាក់របស់រាជការសម្រាប់ទទួលភ្ញៀវពីនានាប្រទេស ឬ ផ្ទះសំណាក់របស់អ្នកជំនួញ សម្រាប់ជួលឲ្យអ្នកដំណើរ ឬក៏សាលារៀនយុទ្ធសាស្ត្រ ។

សតវត្ស (Siècle) (អ.ប. ស:– ត: –វ័ត) ន.

( សំ. ; ម. សតវស្ស ) កំឡុងកាល ១០០ឆ្នាំ, ចំនួនកាល ១០០ ឆ្នាំ ។

អធិ. សតវត្សនេះ < សត « រយ , មួយរយ » + វត្ស « ឆ្នាំ » បានដល់កាលបរិច្ឆេទរាប់តាំងពីមួយឆ្នាំទៅដល់ទីមួយរយឆ្នាំ ( គឺរាប់តាំងពីឆ្នាំទី ១ , ទី ២ , . . រហូតដល់ឆ្នាំទី ១០០ ) ហៅថា ១ សតវត្ស ឧទា . កាលសតវត្សទី៨ នៃគ្រិស្តសករាជ កម្ពុជរដ្ឋយើងរាតអំណាចធំទូលាយ ខាងលិចដល់ទឹកប្រទេសមន ខាងជើងដល់ទឹកប្រទេសចិន ខាងកើតទឹកខាងត្បូងដល់ទឹកមហាសមុទ្រប៉ាស៊ីហ្វិក ។

សត្តឃាត ( Abats n.m.pl. ) ( អ. ប. សត្ត - តៈ - ឃាត ) ន. ( ម. ) សត្វដែលត្រូវសម្លាប់ , សត្វដែលត្រូវពិឃាត ។

អធិ. សត្តឃាតនេះ < សត្ត « សត្វ , អ្នកដែលជាប់នៅ » + ឃាត « សម្លាប់ ; ប្រហារ » បានដល់សត្វ

ដែលគេត្រូវសម្លាប់ផ្តាច់បង់ជីវិត ឬ សត្វដែលគេត្រូវប្រហារជីវិតផ្តាច់យកសាច់លក់ ។

សត្តឃាដដ្ឋាន (Abattoir n.m.) (អ. ថ. ស័ត–ត–ឃា–ដ័ត–ឋាន) ន. (ម.) កន្លែងសម្រាប់សម្លាប់សត្វ, ទីសម្រាប់ប្រហារជីវិតសត្វយកសាច់លក់ ។

អធិ. សត្តឃាដដ្ឋាននេះ < សត្ត «សត្វ, តិរច្ឆាន» + ឃាដ «សម្លាប់» ឋាន «ទី, កន្លែង» បានដល់ទីសម្រាប់សម្លាប់សត្វយកសាច់លក់ឬ កន្លែងសម្រាប់សម្លាប់សត្វយកសាច់លក់ ឧទា. សត្តឃាដដ្ឋាននៅភ្នំពេញមានមួយកន្លែង (ផ្សារកាប់គោ) ។

សតិ (Mémoire n.f.) (អ. ថ. ស:– ) ន. ( ម. ; សំ. ស្មឫតិ) ស្មារតី, ការនឹកឃើញ, ការចាំបាន, ការរលឹកឃើញមិនភ្លេច ។

អធិ. សតិនេះ បានដល់ការនឹកឃើញចាំបាន, ប្រឹ

ប្រយ័ត្នមិនភ្លេចខ្លួន គឺដំណើរស្មារតីរឿងគំនិតសំដៅយកសតិចេតសិកដែលរាប់ជាចេតសិកមួយក្នុងពួកចេតសិក ៥២ ជាគ្រឿងជំនួយរបស់ចិត្ត ។

សទិសនាម (Homonyme n.) (អ. ថ. សៈ ទិ-សៈ –) ន. ( ម.; សំ. សទ្ឫឝនាម ) នាមដែលមានរូបស្មើគ្នា, នាមស័ព្ទមានសំឡេងដូចគ្នា, ឈ្មោះដែលត្រូវគ្នា ។

អធិ. សទិសសព្ទនេះ <សទិស «ដែលដូចគ្នា» + សព្ទសូរ, សំដី, សំឡេង, សំនៀង បានដល់ពាក្យដែលមានសព្ទដូចគ្នា តែបានសេចក្ដីខុសគ្នា ដូចជាខ័នឬខាន់ = ន. ព្រះខាន់រាជ្យ, សំខាន់ ; ខ័ណ្ឌ = ន. មានខ័ណ្ឌដញ្ចាំង, ខ័ណ្ឌសីមា ; ខន្ធ = ន. ខន្ធ៥ ; ការ = ន. ឬ កិ. ការងារ, ការពារខ្លួន; កា = កិ. កាន់សំបុត្រ ; កាណ្ឌ = ន. ព្រះកាណ្ឌ (គ្របៀកក្តេច) ការណ៍ = ន. ទាស់ការណ៍, ថ្លែងការណ៍ ។ ពាក្យថា: ខ័ន ឬខាន់, ខ័ណ្ឌ, ខន្ធ ឬពាក្យថា ការ, កា, កាណ្ឌ, ការណ៍

ជាពាក្យមានសំនៀងត្រូវគ្នា ប៉ុន្តែសរសេរខុសគ្នាហើយមានន័យក៏ផ្សេងពីគ្នា ។ ឃ. គ. ប. ។

សទ្ទពិម្ព ( Disque de photographe ) (អ. ថ .ស័ត–ទៈ– ពិម–ពៈ ឬ–ពិម )ន. ( ម. ) ថាសសំឡេង, រូបដំណាងសំឡេង , ប្រដាប់ផ្ដិតចាប់យកសំឡេង ។

អធិ. សទ្ទពិម្ពនេះ < សទ្ទ « ស្នូរ , សំឡេង , សំនៀង , ភាសា , សំដី » + ពិម្ព « រូបប្រៀប , រូបតំណាង , សំណាក, បែប, បែបយ៉ាង, បែបធៀប, គំរូ...» បានដល់ពុម្ពសំឡេង ឬ ថាសសំឡេង គឺថាសម៉ាស៊ីនដែលគេផ្ដិតយកសំឡេងទៅប្រើការបានគ្រប់យ៉ាង ។ ឃ. គ. ប. ។

សទ្ទពិម្ពាល័យ ( Discot' èque n.f. ) (អ.ថ. ស័ត–ទៈ-ពិម - ពា- ល៉ៃ ) ន. ( សំ. ម.–ល័យ ) កន្លែងលក់ថាសសំឡេង , កន្លែងលក់ថាសម៉ាស៊ីន ។

អធិ. សទ្ទពិម្ពាល័យនេះ < សទ្ទ « ស្នូរ , សំឡេង» + ពិម្ព

"រូបរៀប" + អាលយ « ផ្ទះ, មន្ទីរ ... » បានដល់កន្លែងសម្រាប់លក់ជាសសំឡេង ឬ ផ្ទះលក់ជាសសំណាកសំឡេង (ជាសម៉ាស៊ីនច្រៀង) ។ ឃ. គ. ប. ។

សព្ទានុក្រម (Lexique n. m.) (អ. ថ. ស័ត-តា នុ-ក្រំ) ន. (សំ.; ម. សទ្ទានុក្កម) លំដាប់ស័ព្ទ, លំដាប់ភាសា ។

អធិ. សព្ទានុក្រមនេះ < សទ្ទ « សូរ, សំឡេង, សំនៀង ភាសា, សំដី » + អនុក្រម « តាមលំដាប់ » បានដល់ការរៀបរៀងតាមលំដាប់ភាសា ឬ តាមលំដាប់ពាក្យ ។ ពាក្យនេះជាឈ្មោះសៀវភៅមួយដែលគេរៀបរៀងតាមលំដាប់ព្យញ្ជនៈ ។ ១ . សៀវភៅសព្ទានុក្រមបារាំង-ខ្មែរ ។

សទ្ធា (Foi n.f.) (អ. ថ. ស័ត-ធា) ន. (ម.; សំ. ស្រទ្ធា) ជំនឿ, ការជឿ ។

អធិ. សទ្ធានេះ សំដៅយកជំនឿ គឺសេចក្ដីជឿបុណ្យជឿ

បាប, ជឿកម្មជឿផល ។ ព.ផ្ទ. អសទ្ធា ។

សទ្ធាទាន (Libéralité n.f.) (អ.ថ. ស័ត–ធា-ទាន) ន. (ម.; សំ. ឝ្រទ្ធាទាន) ការឲ្យដោយសទ្ធា, អំណោយដោយសទ្ធា ។

អធិ. សទ្ធាទាននេះ < សទ្ធា "ជំនឿ, ការជឿបុណ្យជឿបាប, ជឿកម្មជឿផល" + ទាន "ការឲ្យ, អំណោយ, ទេយ្យវត្ថុដែលជនគប្បីឲ្យ" បានដល់អំណោយដោយសទ្ធា គឺការឲ្យដោយជំនឿ ។

សន្ត (Saint n.m.) (អ.ថ. សន់-តៈ ឬសន់) ន. (ម) សេចក្ដីស្ងប់, សេចក្ដីស្ងៀមស្ងាត់, ជនអ្នកស្ងប់ ។

អធិ. សន្ត នេះ បានដល់សេចក្ដីស្ងប់ស្ងៀម ឬ ជនអ្នកមានការស្ងៀមស្ងាត់ ។

សន្តនិកេតន៍ (Saint-Siège n.m.) (អ.ថ. ស័ន-តៈ-និ-កេត) ន. (ម.–និកេតន) ការគ្រប់គ្រងសេចក្ដីស្ងប់

ការរក្សាសេចក្ដីស្ងប់ ។

អធិ.សន្តិកេតន៍នេះ < សន្ដ៎ «ស្ងប់, រម្ងាប់, ស្ងប់រម្ងាប់, ស្ងប់ស្ងាត់,សាន្តត្រាណ,រាបទាប» + និកេតន «ការគ្រប់គ្រង,ការរក្សា...» បានដល់ការរក្សាសេចក្ដីស្ងប់ស្ងៀម ឬ សេចក្ដីស្ងប់ ថ្ងៃកធម្មតា ។

សន្តិបាល ( Gardien de la paix ) ( អ. ថ. សន់-តិ-បាល ) ន. ( ម.; សំ.ត្រាន្តិបាល ) អ្នករក្សាសន្តិសុខ,អ្នករក្សាសេចក្ដីស្ងប់ ។

អធិ.សន្តិបាលនេះ < សន្តិ « សេចក្ដីស្ងប់,សេចក្ដីសាន្តត្រាណ,សេចក្ដីរាបទាប» + បាល «អ្នកគ្រប់គ្រង,អ្នកបំបាប់ អ្នកថែរក្សា» បានដល់អ្នករក្សាសេចក្ដីស្ងប់ឲ្យបានសុខសាន្តត្រាណ ។ ឃ.គ.ប. ។

សន្តិសុខ ( Sécurité n.f. ) ( អ. ថ. សន់–តិ–សុក ។ ន. ( ម.; សំ.. ត្រាន្តិសុខ ) សុខដែលកើតអំពីសេចក្ដីស្ងប់,

សេចក្ដីសប្បាយដែលកើតអំពីសេចក្ដីសាន្តត្រាណ ។

អធិ.សន្តិសុខនេះ < សន្តិ «សេចក្ដីស្ងប់, សេចក្ដីសាន្តត្រាណ, សេចក្ដីរាបទាប» + សុខ «សេចក្ដីស្រួល, សេចក្ដីសប្បាយកាយសប្បាយចិត្ត» បានដល់សេចក្ដីសុខសាន្តត្រាណ គឺសេចក្ដីស្រួលកាយសប្បាយចិត្ត ដែលកើតអំពីសេចក្ដីស្ងប់ ឬដែលកើតអំពីសេចក្ដីសាន្តត្រាណឥតមានភ័យ ទឹង ស្រុកកើតចម្បាំង ចោរប្លន់ ស្រុកអត់បាយ ជាដើម ។

សន្តី (Sainte n.f.) (អ.ថ. សន់-តី) ន. (ម.) សេចក្ដីស្ងប់, សេចក្ដីស្ងៀមស្ងាត់, ស្ត្រីអ្នកស្ងប់ ។

អធិ. សន្តីនេះ បានដល់សេចក្ដីស្ងប់ស្ងៀម ឬ ស្ត្រីអ្នកមានសេចក្ដីស្ងៀមស្ងាត់ ។ ម.ព. សន្ត ផង ។

សន្តោស (Indulgent) (អ.ថ. សន់-ដោស) (ម.សំ. សន្តោម ឬ សំតោម,) សេចក្ដីត្រេកអរចំពោះវត្ថុជារបស់ខ្លួន; សេចក្ដីពេញចិត្តតាមមានតាមបាន ។

អធិ. សន្តោស នេះ បានដល់សេចក្ដីត្រេកអរពេញចិត្ត ចំពោះវត្ថុ... ជារបស់ខ្លួន គឺបានប៉ុន្មានល្មមចិត្តប៉ុណ្ណោះមិន វះវាម មិនរកតអាទិ ហួសហេតុ ឬ ហួសទំនង ឧទា. សេចក្ដីសន្តោស, មនុស្សត្រូវមានធម៌សន្តោស ។ល។

សន្ទនា ( Conversation n.f. ou Entretien n.m. )

( អ. ប. សន់-ទៈ-នា ) ន. ( ម. សន្ទនា ឬ សំសន្ទនា ) ការនិយាយគ្នា, ការពោលពាក្យស្រួសរាយរកគ្នា, ការប្រឹក្សាគ្នា ។

អធិ. សន្ទនា នេះ ភាសាខ្មែរយកមកប្រើជា ន. និង កិ., ប្រើជា ន. ត្រូវភ្ជាប់ពាក្យ ការ, សេចក្ដី, ដំណើរពីខាងដើម ដូចជា ការសន្ទនា; សេចក្ដីសន្ទនា ឧទា. ការសន្ទនារវាងខ្មែរ-បារាំង គឺការនិយាយសាកសួរគ្នាទៅវិញទៅមករវាងខ្មែរ-បារាំង ។ បើប្រើជា កិ. ត្រូវប្រើត្រឹមតែ « សន្ទនា » ប៉ុណ្ណោះ ប្រែថា និយាយគ្នា, ពោលពាក្យស្រួសរាយរកគ្នា, ប្រឹក្សាគ្នា ឧទា. ខ្មែរនិងបារាំងសន្ទនាគ្នាអំពីបញ្ហាវិជ្ជាស្ថានបោះត្រាក់ ... ។

សន្ធិសញ្ញា ( Traité n.m. ) ( អ. ថ. សន់-ធិ-ស័ញ-ញ៉ ) ន. ( ម. ) ការធ្វើសន្យាបង្គាប់គ្នា; កិច្ចសន្យាតភ្ជាប់គ្នាៗ

អធ. សន្ធិសញ្ញា នេះ < សន្ធិ «ត, តភ្ជាប់, បង្គាប់» + សញ្ញា» សន្យា, សេចក្ដីសំគាល់, គ្រឿងចំណាំ» បានដល់សញ្ញាបង្គាប់គ្នាជាមិត្តភ័ក្ដិ ឬ ការធ្វើកិច្ចបង្ស្ថានមេត្រីនឹងគ្នា ។ ឧទា. សន្ធិសញ្ញាជាស្ថាពរ ( Traité définitif ) ៗ

សន្និច្ច័យសង្គ្រោះ ( prévoyance sociale ) ( អ.ថ. សន់-និច-ចៃ-សង់-គ្រោះ ) ន. ( ម. សំ. កូ. ) ការសន្សំទុកជួយសង្គ្រោះ; ការសំចៃទុកជួយទំនុកបម្រុង ៗ

អធ. សន្និច្ច័យសង្គ្រោះ នេះ < សន្និច្ច័យ ( ម. សន្និច្ច័យ; សំ. សំនិច្ឆយ ឬ សន្និច្ឆយ )» ការសន្សំទុក ; ការសំចៃទុក ឬ ការទុកសំចៃ» + សង្គ្រោះ ( ម. សង្គហ; សំ. សំគ្រហ ឬ សង្គ្រហ ; ហ > ះ )» ការទំនុកបម្រុង, ធុរធ្ដើម, ស្រោចស្រង់ ជួយឲ្យបានសុខស្រួល» បានដល់ការសន្សំ សៃលកទុកជួយ

ទំនុកបម្រុង ឬ ការសំចៃទុកជួយសង្គ្រោះ ។

សន្និដ្ឋាន ( Conclusion n.f. ) ( អ. ថ. សន់–និត–ឋាន ) ន. ( ម.; សំ. សំនិដ្ឋាន ឬ សន្និដ្ឋាន ) សេចក្ដីចូលចិត្ត; ការយល់ជាក់, ការយល់ឃើញស៊ប់, ការរួមគំនិតជាមួយ

អធិ. សន្និដ្ឋាន នេះ បានដល់សេចក្ដីចូលចិត្តស៊ប់ ឬ ការ-យល់ឃើញជាក់លាក់តាមគំនិតរបស់ខ្លួន ដែលបានពិនិត្យសង្កេតអត្ថប្រយោជន៍ផ្សេងៗ ។

សន្និធិ ( Stock n.m. ) ( អ. ថ. សន់–និ– ) ន. ( សំ. ម. សំនិធិ ឬ សន្និធិ ) ការសន្សំទុក, ការសំចៃទុក ឬ ការទុកសំចៃ ។

អធិ. សន្និធិ នេះ បានដល់វត្ថុដែលបន្សល់ទុក ឬ របស់សំចៃបែលកទុកដាក់ ។

សន្និបាត ( Réunion n.f. ) ( អ. ថ. សន់–និ–បាត ) ន. ( ម.; សំ. សំនិបាត ឬ សន្និ– ) ការប្រជុំ, ការជួបជុំ; ការ

ប្រមូលប្រមូលគ្នា ។

អធិ. សន្និបាតនេះ សំដៅយកការប្រមូលគ្នាប្រជុំប្រមូលធ្វើ
កិច្ចការផ្សេងៗ ឬ បានដល់ពួកក្រុមជំនុំពិនិត្យការងារទាំងពួង ។

សន្និសីទ (Conférence) (អ. ថ. សន់–និ–បាត)
ន. (ម.; សំ. សំនិប័ទ ឬ សន្និ–) ការប្រជុំ; ការអង្គុយសិប;
ការអង្គុយនៅស្ងៀម ។

អធិ. សន្និសីទនេះ បានដល់ការប្រជុំគ្នាស្ដាប់សេចក្ដីថ្លែង
ការណ៍របស់ជនណាមួយ ឬ ការអង្គុយនៅស្ងៀមប្រុងស្ដាប់
សេចក្ដីថ្លែងសារប្បវត្តិរបស់ជនណាមួយជាអ្នកថ្លែងប្រាប់ ។ ឧទា.
សន្និសីទរវាងជាតិ (Conférence internationale) សន្និសីទ
អន្តររដ្ឋ (Conférence-inter-Etat) ។ល។

សព្ទ ឬ សព្ទ៍ (Terme n.m.) (អ. ថ. ស័ប) ន.
(សំ. ឝព្ទ; ម. សទ្ទ) សូរ, សំឡេង, សំនៀង, ភាសា
ពាក្យ; សំដី; សម្រែក ។

អធិ · សព្ទ ឬ ស័ព្ទនេះ   បានដល់ពាក្យដែលនិយាយមួយពាក្យៗ ឬ សំនៀងភាសាមួយពាក្យ ៗ ឧទា.ស័ព្ទបច្ចេកទេស(Terme technique)ៗរាជស័ព្ទ (Terme royal)។

សំញាវុធ( Armement )( អ·ប. សាប់–ញា–វុត ) ន. ( ម· ) អាវុធគ្រប់យ៉ាង ; គ្រឿងប្រហារគ្រប់បែប ។

អធិ. សញ្ញាវុធនេះ < សព្វ « ទាំងអស់ , ទាំងពួង , ទាំងមូល , ទាំងស្រុង , ទាំងគ្រប់ , គ្រប់ , គ្រប់យ៉ាង , ទូទៅ , រាល់ » + អាវុធ « គ្រឿងប្រហារ ឬគ្រឿងចម្បាំងផ្សេង ៗ » បានដល់អាវុធគ្រប់យ៉ាង មានធ្នូ–ស្នា–កាំភ្លើងជាដើម ដែលជាគ្រឿងសម្រាប់ប្រហារជីវិតមនុស្សសត្វ ។

សំភា (Parlement n.m.) ( អ. ប. ស: – ) ន· ( សំ· ម· ) ទីប្រជុំ , ការប្រជុំ , ទីសម្រាប់ប្រជុំ ពិភាក្សាកិច្ចការ ; សមាគម ។

អធិ. សភានេះ សំដៅយកទីប្រជុំ គឺកន្លែងមានមន្ត្រី ឬ

សាលា ជាដើម ដែលគេសម្រាប់ប្រជុំពិភាក្សាការផ្សេងៗ ។

សភាគ ( Homogène adj. ) ( អ. ប. សៈ-ភា-គៈ ឬ សៈ-ភាក ) គុ. ( ម. ) ដែលមានចំណែកស្មើគ្នា គឺដែលត្រូវគ្នា, ដូចគ្នា; ដែលត្រូវចិត្តត្រូវគំនិតគ្នា, ដែលស្និទ្ធស្នាលនឹងគ្នា

អធិ. សភាគនេះ ប្រើជា ន. ថា: មនុស្ស, សត្វ ឬ អ្វីៗ ដែលត្រូវគ្នា, ដូចគ្នា, ស្មើគ្នា ។ ឧទា. មនុស្សទាំងពីរនាក់នុះជាសភាគនឹងគ្នា ។ ព. ផ្ទុ. វិសភាគ ។

សភានុពន្ធ ( Attaché parlementaire ) ( អ. ប. សៈ-ភា-នុ-ព័ន ) ន. ( ម.-ពន្ធ ) ការរួបរួមគ្នាប្រជុំ ; ការចងភ្ជាប់គ្នាប្រជុំ ។

អធិ. សភានុពន្ធនេះ < សភា«ទីប្រជុំ, ការប្រជុំ, ទីសម្រាប់ប្រជុំពិភាក្សាកិច្ចការ» + អនុពន្ធ« ចងការរួមគ្នា, ការជាប់តាមលំដាប់ . . .» បានដល់ការរួបរួមគ្នាប្រជុំ ឬ ការប្រមូលចងភ្ជាប់គ្នាប្រជុំពិភាក្សាកិច្ចការផ្សេងៗ ។

**សភាបញ្ញត្ត** ( Assemblée constituante ) ( អ.ថ. ស:-ភា-ប័ញ-ញ៉ាត់ ) ន. ( ម. ) សភាតាំងច្បាប់ ; ទីប្រជុំតែងតាំងច្បាប់ ។

អធិ. សភាបញ្ញត្តនេះ < សភា « ទីប្រជុំ, ការប្រជុំ, ទីសម្រាប់ប្រជុំពិភាក្សាកិច្ចការ » + បញ្ញត្ត « ហាមប្រាម, តែងតាំង, តាំងទុក, រៀបចំ » បានដល់សភាសម្រាប់តែងតាំងច្បាប់ប្រតិបត្តិ ឬ ទីសម្រាប់ប្រជុំពិភាក្សាគ្នាបញ្ញត្តច្បាប់ ។

**សភាវគតិ** ( Instinct ) ( អ. ថ. ស:-ភា-វ:-គ:-តិ ) ន. ( ម. ) គតិធម្មតា ; ដំណើរកើតឯង ; ដំណើរធម្មតា ។

អធិ. សភាវគតិនេះ < សភាវ « ដំណើរកើតឯង, ធម្មតា, ធម្មជាតិ, ប្រក្រតី, អាស្រ័យ, ការតាំងចិត្ត, ហេតុ, ការណ៍ ការប្រព្រឹត្ត, សេចក្ដីពិតតាមធម្មតា » + គតិ « ដំណើរ, លំនាំ... » បានដល់គតិជាធម្មតា គឺដំណើរដែលកើតឯង មិនផ្លាស់ប្ដូរ មិន

ប្រែប្រួល គឺដំណើរប្រក្រតី ។ តាមសភាវគតិ ( Instinctivement adv. ) ។

សភាវនីតិ ( Esprit n.m. ) ( អ. ថ. ស:–ភា–វ:-នី–តិ ) ន. ( ម.; សំ. ស្វភាវនីតិ ) សភាពនៃច្បាប់ ឬ ដំណើរនៃច្បាប់ធម្មតា ; ដំណើរនៃនីតិសាស្ត្រ ។

អធិ: សភាវនីតិនេះ < សភាវ « ដំណើរកើតឯង, ធម្មតា, ធម្មជាតិ, ប្រក្រតី, អធ្យាស្រ័យ, ការតាំងចិត្ត ហេតុ, ការណ៍, ការប្រព្រឹត្ត, សេចក្ដីពិតតាមធម្មតា » + នីតិ « ច្បាប់, សិទ្ធិ, នីតិសាស្ត្រ » បានដល់ច្បាប់ដែលកើតធម្មតា ឬ ដែលកើតឯង ។

សភាវិសាមញ្ញ (Assemblée extraordinaire)(អ. ថ. ស–ភា–វិ–សា–មុំញ ) ន. ( ម. – វិសាមញ្ញ ) ការប្រជុំប្លែកពីធម្មតា, ការប្រជុំខុសប្រក្រតី ។

អធិ. សភាវិសាមញ្ញនេះ < សភា « ទីប្រជុំ, ការប្រ

ជុំ , ទីសម្រាប់ប្រជុំ, ពិភាក្សាកិច្ចការ ›› + វិសាមញ្ញ ‹‹ ដែលប្លែកពីធម្មតា ឬ ពីសព្វដង, ដែលខុសប្រក្រតី, ដែលមិនមែនជាសាធារណៈ , មិនទូទៅ ›› បានដល់ការប្រជុំដែលខុសប្រក្រតី ដែលប្លែកពីធម្មតា ឬ ពីសព្វដង ។

សភាសហភាព (Assemblée de l'Union) (អ. ថ. សៈ–ភា– សៈ– ហៈ – ភាវ ) ន. ( សំ . ម. –ភាវ) ភាពនៃការប្រជុំជាមួយគ្នា , ភាពនៃទីសម្រាប់ប្រជុំពិភាក្សាកិច្ច-ការរួមជាមួយគ្នា ។

អធិ. សភាសហភាពនេះ < សភា ‹‹ ទីប្រជុំ, ការប្រជុំ, ទីសម្រាប់ប្រជុំ ពិភាក្សាកិច្ចការ›› + សហ ‹‹ មួយអន្លើ, ព្រម, ព្រមដោយ, ព្រមទាំង, ជាមួយ, ជាមួយគ្នា, ជាមួយនឹង រួមគ្នា, រួមជាមួយ; ដំណាល›› + ភាព ‹‹ភាវៈ, បែបបទ, លំនាំ, ឫកពាៈ...›› បានដល់ភាពនៃទីប្រជុំដែលរួមជាមួយគ្នា ឬ ភាពនៃការប្រជុំដែលជាប់ទាក់ទងជាមួយគ្នា ។

សភាសាមញ្ញ (Assemblée ordinaire) (អ. ថ. ស:-ភា-សា-ម៉ុញ) ន. (ម.; សំ. សភាសាមាន្យ) សភា, ធម្មតា, ទីសម្រាប់ប្រជុំជាធម្មតា, ការប្រជុំប្រក្រតី ។

អធិ. សភាសាមញ្ញនេះ < សភា « ទីប្រជុំ, ការប្រជុំ, ទីសម្រាប់ប្រជុំ, ពិភាក្សាកិច្ចការ » + សាមញ្ញ « សាធារណៈ; ដែលជាធម្មតា, ដែលស្មើៗ តែគ្នា, ដែលរាប់រយរាប់ពាន់ » បានដល់ទីប្រជុំជាធម្មតា ឬ ការប្រជុំជាធម្មតា គឺទីសម្រាប់ប្រជុំជាចំនៀមហូរហែគ្មានប្លែកពីប្រក្រតី ។

សមណទូត (Nonce n.m.) (អ. ថ. ស:- ម:-ណ:) ន. (ម.) ទូតសាសនា គឺអ្នកបួសជាសមណៈបំរើសាសនា ឬ អ្នកបម្រើរបស់អ្នកស្ងប់រម្ងាប់ ។

អធិ. សមណទូតនេះ < សមណ « អ្នកមានព្យាយាមដុតកំដៅបាប, អ្នកស្ងប់, អ្នករម្ងាប់បាប (អ្នកបួស) » + ទូត « អ្នកដែលគេបញ្ជូនទៅ, ដែលគេប្រើទៅ, អ្នកនាំការ, នាំ

ដំណឹងពីម្នាក់ទៅម្នាក់ ” បានដល់ទូតខាងសាសនា គឺអ្នកបម្រើផ្នែកសាសនាដែលគេប្រើទៅជាតំណាង ដើម្បីទៅពិភាក្សាការផ្សាល់នឹងអ្នកកាន់សាសនាក្នុងប្រទេសដទៃ ។

សមណៈប្រេសិត (Légat) (អ. ច. ស:-ម:-ណ:-) ន. (ម.- បេសិត ; សំ. ស្រមណប្រេសិត) សមណៈដែលគេបញ្ជូនទៅ , អ្នកបួសដែលគេប្រើឲ្យទៅ ។

អធិ. សមណៈប្រេសិតនេះ < សមណ ” អ្នកស្ងប់ , អ្នករម្ងាប់បាប (អ្នកបួស) ... ” + ប្រេសិត “ ដែលគេបញ្ជូនទៅ ; ដែលគេប្រើទៅ ” បានដល់អ្នកបួសដែលគេបញ្ជូនទៅ ១ទា. សមណៈប្រេសិតរបស់បាប (Légat du Pape) ។

សមត្ថកម្ម ឬ សមត្ថកិច្ច (Compétence n.f.) (អ. ច. ស:- ម៉ុត-ថ:-) ន. (ម. ) អំពើដែលអាចធ្វើកើតឬការងារដែលគេអាចធ្វើដោយខ្លួនឯង ។

អធិ. សមត្ថកម្ម ឬ សមត្ថកិច្ចនេះ < សមត្ថ «ដែលអាច, ដែលអាចហ៊ាន, ដែលធ្វើកើត» + កម្ម ឬ កិច្ច «អំពើ, ការងារដែលត្រូវធ្វើ; ការរវល់» បានដល់ការងារដែលគេអាចធ្វើកើត ឬ ដែលអាចសម្រេចបាន ។

សមត្ថភាព (Capacité n.f.) (ស. ថ. ស:. ម៉ត់-ថ-ភាព)ន. (សំ. ម.- ការ) ភាពនៃសេចក្ដីអង់អាច, ភាពនៃសេចក្ដីមោះមុត, ក្លៀវក្លា ។

អធិ. សមត្ថភាពនេះ < សមត្ថ «សេចក្ដីអង់អាច, សេចក្ដីអាចហ៊ាន ឬ ហ៊ានក្លា, ដំណើរធ្វើកើត» + ភាព ការៈ បែបបទ, លំនាំ, ឫកពា...» បានដល់ភាពនៃមនុស្ស ឬសត្វដែលមានសេចក្ដីអាចហ៊ាន សេចក្ដីមោះមុតអាចពុះពារនូវឧបស័គ្គដែលជាសត្រូវចំពោះខ្លួន ។

សមភាព (Égalité n.f. ou Équité n.f.) (ស. ថ. ស:-ម៉:-)ន. (ម.- ការ) ភាពដ៏ស្មើគ្នា, ដំណើរស្មើមុខគ្នា,

ភាពនៃវត្ថុដ៏ស្មើ ៗ

អធិ. សមភាពនេះ ‹សម «ស្មើ, ពបស្មើ ...» + ភាព «ភាវៈ, បែបបទ, លំនាំ, ឬកពា...» ប្បានដល់វត្ថុឬធម្មជាតិអ្វីដែលស្មើគ្នា ដូចគ្នា ត្រូវគ្នា សមគ្នា ៗ សមភាពនេះ មាន ៤យ៉ាង គឺ:– កិច្ចសមភាព ភាពស្មើគ្នាដោយកិច្ច គឺដំណើរមានកិច្ចការ ឬ មុខការរបស់ស្មើគ្នា, ២– អានុភាវសមភាព ភាពស្មើគ្នាដោយអានុភាព គឺការមានអំណាចស្មើគ្នា, ៣– សីលសមភាព ភាពស្មើគ្នាដោយសីល គឺដំណើរកាន់សីល ឬ មានមារយាទល្អស្មើគ្នា, ៤ – ទិដ្ឋិសមភាព ភាពស្មើគ្នាដោយទិដ្ឋិ គឺដំណើរមានប្រាជ្ញាយល់ការពិតស្មើគ្នា ។ល។

សមហេតុសមផល ( Raisonnable abj.)(ស. ប. សំ–ហេតុ–សំ–ផល) គុ. (ម) ដែលត្រូវហេតុ, ដែលស្មើហេតុស្មើផល ៗ

អធិ. សមហេតុសមផលនេះ ប្បានដល់របស់ដែលគេពិនិត្យ

សង្កេតមើលឲ្យឃើញហេតុផល ឲ្យត្រូវទំនង់ដើមបមចុង-គល់គ្នា ឲ្យសមបែបបទខាងដើមដែលបណ្ដាលឲ្យផលសមគ្នា ។

សម្បជញ្ញៈ (Conscience psychologique) (អ. ថ. ស័ម-ប៉ះ-ជ័ញ-ញៈ) ន. (ម. សម្បជញ្ញៈ; សំ. សំប្រជ្ញ, សំប្រជ្ញា ឬ សម្ប្រ-) សេចក្ដីដឹងខ្លួន, ការមិនភ្លេចខ្លួន, ការប្រុងប្រយ័ត្នជានិច្ច, ការត្រិះរិះពិចារណាដឹងខ្លួនជាដរាប ។

អធិ. សម្បជញ្ញៈនេះ បានដល់ការដឹងខ្លួនជានិច្ច មិនមានភ្លេចជាលក្ខណៈ គង់វេលាធ្វើ វេលានិយាយ វេលាគិតនូវកិច្ចានុកិច្ចដែលត្រូវធ្វើ ត្រូវនិយាយ ត្រូវគិតនោះៗ មិនឲ្យខូចខាត ។ ប្រើជា គុ. ថា: មានសម្បជញ្ញៈ (Conscieneux adj,) ។

សម្បទ ឬ សម្បទា (Aptitude) (អ. ថ. ស័ម-ប័ទ ឬ ស័ម-ប៉ះ-ទា) ន. (ម. សម្បទ ឬ សម្បទា) ការដល់ព្រម, ការគ្រប់ព្រម ឬ គ្រប់គ្រាន់, ការបរិបូណ៌,

ការសមប្រកប ។

អធិ. សម្ប័ទ ឬ សម្បទានេះ បានដល់គុណជាតិជាគ្រឿងសម្រេចប្រយោជន៍ ឬគុណសម្ប័ទ ៤ យ៉ាង គឺការខំ-ប្រឹងប្រកបកិច្ចការមិនខ្ជិលច្រអូស, ការរក្សាទ្រព្យ, ការគប់រកមនុស្សល្អជាគ្នា, ការចាយវាយទ្រព្យធនត្រូវបែបបទ ។

សម្បទាន (Consession) (អ. ថ. ស័ម-ប៉ៈ-) ន. (ម.; សំ. សំប្រទាន ឬ សម្ប្រទាន) ការប្រគល់ឲ្យ, ការឲ្យដល់ដៃ, ការឲ្យដាច់, ការទទួលអំណោយ ។

អធិ. សម្បទាននេះ បានដល់ការប្រគល់ឲ្យនូវសម្បាច់គ៏ទ្រព្យកេរ្តិ៍របស់ជាដំណែល ។ ឧ. សម្បទានអណ្តូងរ៉ែ (Consession miniere) ។ អ្នកទទួលសម្បទាន (Consessionnaire) ។

សម្ពន្ធ ឬ សម្ព័ន្ធ (Analyse n.f.) (អ. ថ. សំ-ព័ន-ធៈ ឬ សំ-ព័ន) ន. (សំ. ម. សម្ពន្ធ) ការចង

ភ្ជាប់គ្នា , ការតភ្ជាប់គ្នា , ដំណើរទាក់ទងរកគ្នា ។

អធិ. សម្ពន្ធ ឬ សម្ព័ន្ធនេះ បានដល់ពាក្យវេយ្យាករណ៍ ថា ការទាក់ទងរបស់សព្ទក្នុងប្រយោគ ឬ ចំណងប្រយោគ គឺ ការចងបទក្នុងប្រយោគមួយ ៗ ឲ្យដឹងថាបទណាចូលទៅរកបទ ណា , បទណាជាប្រធាន , ណាជាកិរិយា , ណាជាកំពើ ជា ដើម ដូចជា: ស្រី ទៅ ទិញ ត្រី ឯផ្សារ , សម្ពន្ធថា: ស្រី ជាប្រធានរបស់ ទៅ , ទៅ ជាកិរិយារបស់ស្រី , ទិញ ជា កិរិយាប្រាប់បំណងរបស់ ទៅ ( ទៅដើម្បីទិញ ) , ត្រី ជា កំពើរបស់ ទិញ , ឯ–ផ្សារ ជាការយេតនិបាតប្រាប់ទី ( ដែល ត្រូវទិញត្រី ) ។

**សម្ព័ន្ធកីឡា** ( Ligue sportive ) ( អ. ថ. សំ–ព័ន កី–ឡា ) ន. ( ម. សម្ពន្ធកីឡា ) ល្បែងដែលរួបរួមគ្នា ឬ ការ ចងភ្ជាប់គ្នាខាងល្បែង ។

អធិ. សម្ព័ន្ធកីឡានេះ < សម្ពន្ធ « ការចងភ្ជាប់គ្នា , ការ

តភ្ជាប់គ្នា ; ដំណើរទាក់ទងគ្នា „ + កីឡា „ ល្បែង , ការលេង , បានដល់ដំណើរចងភ្ជាប់គ្នាខាងល្បែង ឬ ការល្បែងដែលចងភ្ជាប់ប្រួមគ្នា ។

**សម្ពន្ធភាព** ( Alliance n.f. ) ( អ. ថ. សំ–ព័ន–ធៈ–ភាប ) ន. ( ម. – ភាវ ) ភាពនៃការចងភ្ជាប់គ្នា ; ភាពនៃការទាក់ទងគ្នា ។

អធ. សម្ពន្ធនេះ < សម្ពន្ធ „ ការចងភ្ជាប់គ្នា , ការតភ្ជាប់គ្នា , ដំណើរទាក់ទងគ្នា „ + ភាព „ ភាវៈ ; បែបបទ , លំនាំ , ឫកពា ... „ បានដល់ភាពនៃការចងគ្នាជាពួក ឬ ភាពនៃដំណើរទាក់ទងគ្នាទៅវិញទៅមក ។

**សម្មតិកម្ម** ( Hypothèse n.f. ) ( អ. ថ. ស័ម–មៈ–តិ–ក័ម ) ន. ( សំ. ម. ) អំពើដែលគេសន្មត , អំពើដែលគេប្ដេជ្ញា , ការដែលគេអនុម័ត , ការណ៍ដែលគេកំណត់ ។

អធ. សម្មតិកម្មនេះ < សម្មតិ „ សន្មត ,

ប្តេជ្ញា , សន្យា , អនុម័ត , យល់ព្រម , ព្រមតាម , កំណត់ » + កម្ម « អំពើ , ការងារដែលគេត្រូវធ្វើ » បានដល់អំពើដែលគេសន្មត គឺការងារដែលគេកំណត់ ឬដែលគេប្តេជ្ញា ។

សមាគតរដ្ឋ ( Etat associé ) ( អ. ថ. ស:-មា៉គ:-ត:-រ័ត ) ន. ( ម. ) រដ្ឋដែលមកព្រមហើយ , ប្រទេសដែលរួបរួមកិច្ចការជាមួយគ្នា ។

អធិ. សមាគតរដ្ឋនេះ < សំ « ព្រម » ០ > ម + អាគត « ដែលមកហើយ » > សមាគត « ដែលមកជួបជុំ ដែលរួមចូលគ្នា , ដែលរួមកិច្ចការជាមួយគ្នា » + រដ្ឋ « ដែន, ប្រទេស ... » បានដល់រដ្ឋដែលចូលរួមកិច្ចការជាមួយរដ្ឋណាមួយ ឬ ប្រទេសដែលនៅរួមចូលក្នុងមហារដ្ឋណាមួយ ។

សមាគម ( Association ) ( អ. ថ. ស : - មា៉ - គំ ) ន. (សំ. ម.) ការមកជួបជុំ , ការប្រជុំ , ការរួមគំនិត

គ្នា ; ដំណើររួបរួមកិច្ចការជាមួយគ្នា ។

អធិ. សមាគមនេះ < សំ « ព្រម », ១ > ម + អាគម « ការមក , ដំណើរមក » បានដល់ការរួមគំនិតគ្នា ឬការរួបរួមចូលហ៊ុនគ្នាធ្វើអ្វីផ្សេងៗ ។

សមាគមអាកាសយាន (Aéro-club) (អ. ច. សះ-មា-គំ-អា-កាះ-) ន. (ម) ក្រុមហ៊ុនអាកាសយាន, ការរួមគំនិតគ្នាខាងយន្តហោះ ។

អធិ. សមាគមអាកាសយាននេះ < សមាគម « ការរួមគំនិតគ្នា , ដំណើររួបរួមកិច្ចការជាមួយគ្នា, ក្រុមហ៊ុន » + អាកាសយាន « យានដែលសញ្ចរទៅតាមអាកាស, ជំនិះដែលហោះហើរទៅតាមអាកាស, យន្តហោះ » បានដល់ក្រុមហ៊ុនខាងអាកាសយាន គឺពួកជនអ្នករួមគំនិតគ្នាខាងជំនិះទៅតាមផ្លូវអាកាស ឬក្រុមហ៊ុនខាងយន្តហោះដឹកនាំគ្រឿងផ្សេងៗ តាមផ្លូវអាកាស ។

សមាជ (Congrès n.m.) (ឝ. ថ. ស:–មា៉ច) ន. (ម.) ទីប្រជុំ, កន្លែងសម្រាប់ប្រជុំពួកសមាជិក, កន្លែងដែលសមាជិកបង្កើតសម្រាប់ជំនុំ ។

អធិ. សមាជនេះ បានដល់ទី ឬ កន្លែងដែលពួកសមាជិកបង្កើតសម្រាប់សមាគម ឬ សមាគមប្រជុំប្រឹក្សាកិច្ចការផ្សេងៗ

សមាជិក ( Membre n.m.) (ឝ. ថ ស: មា៉-ជិក ) ន. ( សំ . ម . ) អ្នកដែលមានអំណាចត្រូវចូលកាន់ទីប្រជុំបាន , អ្នកចូលក្នុងសមាគម ; អ្នកបង្កើតសមាជ ។

អធិ. សមាជិកនេះ បានដល់ជនអ្នកមានអំណាចត្រូវចូលទៅកាន់ទីប្រជុំបាន ឥតមានអ្នកណាហាមឃាត់ ឬ ជនអ្នកបង្កើតសមាជ ឧទា. សមាជិកកិត្តិយស ( Membre d'honneur ) ។ សមាជិករដ្ឋាភិបាល ( Membre du Gouvernement ) ។ សមាជិកសភា ( Membre parlementaire ) ។ សមាជិកអ្នកឆ្លើយឆ្លង ( Membre correspondant ) ។ គម្ម

កសមាជិក ( Membre actif ) ។ ជនកសមាជិក ( Membre-fondateur ) ។ ទាយកសមាជិក ( Membre donateur ) ។ ឧបាទិកសមាជិក ( Membre sympathisant ) ។ យុទ្ធិកសមាជិក ( Membre militant ) ។ សង្គមិកសមាជិក ( Membre sociétaire ) ។ សមាទិកសមាជិក ( Membre souscripteur ) ។ល។

សមាជិកបណ្ឌិតសភា ( Académicien ) ( អ. ថ. ស: – មា – ជិក – បន់ – ឌិត – ស: – ) ន. ( ម. ) សមាជិកខាងការប្រជុំអ្នកប្រាជ្ញ ឬ សភាសម្រាប់សមាជិកខាងអ្នកប្រាជ្ញ ។

អធិ. សមាជិកបណ្ឌិតសភានេះ < សមាជិក "អ្នកចូលក្នុងសមាគម, អ្នកបង្កើតសមាជ, អ្នកធ្វើឲ្យកើតព្រម" + បណ្ឌិត "អ្នកចេះ; អ្នកប្រាជ្ញ" + សភា "ទីប្រជុំ, ការប្រជុំ, ទីសម្រាប់ប្រជុំពិភាក្សាកិច្ចការ

បានដល់សមាជិកខាងទីសម្រាប់ប្រជុំ ពិភាក្សារបស់អ្នកប្រាជ្ញ ។

**សមាជិកព្រឹទ្ធសភា** (Sénateur n. m.) (អ. ថ. ស: - មា - ជិក - ព្រឹត - ធេ:-ស: - ) ន. (សំ. សមាជិកវ្ឫទ្ធសភា; ម. សមាជិកវុឌ្ឍសភា) សមាជិករបស់សភាដ៏មាំមួន, អ្នកបង្កើតអ្វី ៗ ខាងព្រឹទ្ធសភា ។

អធិ. សមាជិកព្រឹទ្ធសភានេះ < សមាជិក « អ្នកចូលក្នុងសមាគម, អ្នកបង្កើតសមាជ, អ្នកធ្វើឲ្យកើតព្រម » + ព្រឹទ្ធសភា « ទីប្រជុំដ៏មាំមួន, ការប្រជុំដ៏ខ្ជាប់ខ្ជួន, ទីសម្រាប់ប្រជុំ ពិភាក្សាកិច្ចការដ៏ចម្រើន » បានដល់អ្នកដែលមានអំណាចត្រូវចូលកាន់ទីសម្រាប់ប្រជុំដ៏មាំមួន ឬ អ្នកប្រជុំដែលចម្រើនដោយសមាជិក ។

**សមាធិ** ( Concentration n.f. ) ( អ. ថ. ស: - មា - ) ន. ( សំ. ម. ) ដំណើរតាំងស៊ប់មាំនៃចិត្ត ; ការទឹករំពឹងស្ងប់ចិត្ត ។

អធិ. សមាធិនេះ បានដល់ការតាំងចិត្តឲ្យស្លុងចុះស៊ប់ក្នុងគន្លងអារម្មណ៍ដែលនឹករំពឹង ឬ ការដំកល់ចិត្តឲ្យចុះស៊ប់នៅនឹងក្នុងអារម្មណ៍តែមួយ , ដំណើរស្លុងចិត្តស៊ប់ក្នុងអគ្គឈាន ។

សមានចិត្ត ( Sympathie n.f. ) ( អ. ថ. ស : –មា៉ន : – ចិត ) ន. ( ម. ) ចិត្តស្មើ , ចិត្តស្មើគ្នា , ប៉ុនគ្នា , ដូចគ្នា ។

អធិ. សមានចិត្តនេះ < សមាន « ដែលស្មើគ្នា , សមគ្នា . . . » + ចិត្ត « ធម្មជាតដែលត្រិះរិះ ឬ សន្សំនូវអារម្មណ៍ » បានដល់ចិត្តដែលស្មើគ្នា ប៉ុនគ្នា ដូចគ្នា ។

សមានាចារ្យ ( Condisciple ) ( អ. ថ. ស : – មា៉នា – ចា ) ន. ( ម. សមានាចរិយ ; សំ. សមានាចាយ៌ ) អាចារ្យស្មើគ្នា , អាចារ្យជាមួយគ្នា , អ្នកដែលមានគ្រូជាមួយគ្នា ។

អធិ. សមានាចារ្យនេះ < សមាន « ដែលស្មើ ,

ស្មើគ្នា , ប៉ុនគ្នា , ដូច , ដូចគ្នា , ជាមួយគ្នា , ដែលត្រូវគ្នា » + អាចារ្យ « អ្នកប្រដៅ ឬ ហាត់មារយាទ ; អ្នកប្រព្រឹត្តល្អ ; អ្នកកាន់ត្រឹមត្រូវ , អ្នកត្រឹមត្រូវ ; អ្នកដែលសិស្សត្រូវគោរព , អ្នកធ្វើប្រយោជន៍ដល់សិស្ស , អ្នកបង្រៀនបំណោះគេ , គ្រូ , គ្រូបង្រៀន » បានដល់អាចារ្យដែលស្មើគ្នា ឬ អ្នកដែលមានគ្រូអាចារ្យជាមួយគ្នា ។

សមាសភាព (Composition) (អ. ថ. ស:- ម៉ា- ស:- ) ន. ( សំ. ម. -- ភាវ ) ភាពនៃការបង្រួមចូល , ភាពនៃការបំប្រួញឱ្យខ្លី ។

អធ. សមាសភាពនេះ< សមាស «ការបង្រួមចូល , ការបំប្រួញឱ្យខ្លី , ឱ្យតិចចុះ , ឱ្យសង្ខេប » + ភាព «ភាវ: , បែបបទ , លំនាំ , ឫកពា - - - » បានដល់ភាពនៃការបង្រួម សេចក្ដីបំប្រួញឱ្យខ្លី ឬ ឱ្យសង្ខេបចុះមក ។

**សម្ភារៈ** (Matériel n.m.) (អ. ថ. សំម-ភា-រៈ) ន. (សំ. ម. សម្ភារ) វត្ថុជាទម្ងន់ ; បន្ទុក ; គ្រឿងប្រដាប់ ។

អធិ. សម្ភារៈនេះ < សំ « ព្រម », … > ម + ភារ « ទម្ងន់, បន្ទុក, គ្រឿងប្រដាប់ ---- » បានដល់ការសន្សំ ឬ ការសាងសន្សំកុសល ; គ្រឿងផ្សំ, គ្រឿងផ្គុំ, គ្រឿងប្រដាប់ ; តេជៈ, អំណាច, សេចក្ដីទំនុកបម្រុង ; គ្រោចស្រង់ជាដើម. ឧទា. សម្ភារៈយាន (Matériel roulant) ។ល។

**សម្ភាសន៍** (Interview n.m.) (អ.ថ. សំ-ភាស) ន. (ម. សម្ភាសន ; សំ. សម្ភាបណ) ការនិយាយនឹងគ្នា, ការរាក់ទាក់នឹងគ្នា ; ពាក្យសសោះអន្ទង៍ ; សំដីឆ្លើយឆ្លង ឬ សាសន៍ដោយលំអុត ; សល្លាបកថា, សង្កថា ។

អធិ. សម្ភាសន៍នេះ < សំ « ព្រម », ខ > ម + សភាន « ការនិយាយ, បរបា, ពាក្យ, សំដី » បានដល់ការនិយាយរាក់ទាក់រកគ្នា ឬ សំដីបរបារស្រាយទៅវិញទៅមករកគ្នា ។

សម្មាភាគ ( Rapport n.m. ) ( អ. ថ. ស័ម – មា៉ ភាគ ) ន. ( ម. ) ចំណែកដោយប្រពៃ, ការចែកដោយត្រឹមត្រូវ ; សេចក្ដីរាយការ ។

អធិ. សម្មាភាគនេះ < សម្មា « ដោយប្រពៃ, ល្អ, ស្រួល, ត្រឹមត្រូវ » + ភាគ « ចំណែក, ការបែងចែក ... » សំដៅយកចំណែកដ៏ត្រឹមត្រូវ គឺការចែកសេចក្ដីរាយការដោយត្រឹមត្រូវល្អ ។

សម្មាមាត្រ ( Proportion n.f. ) ( អ. ថ. ស័ម – មា៉ – មាត ) ន ( សំ. ; ម. សម្មាមត្ត ) ទំហំដ៏ត្រឹមត្រូវ, ការរាប់ដ៏ត្រឹមត្រូវ, ខ្នាតរង្វាស់ដ៏ត្រឹមត្រូវ ។

អធិ. សម្មាមាត្រនេះ < សម្មា «ដោយប្រពៃ» + មាត្រា «រូបរាង, រូបសណ្ឋាន, ទំហំ, ការកាប់, ការថ្លឹង, ស្ទង់, ការ-វាស់, ខ្នាតរង្វាស់» បានដល់មាត្រាដ៏ត្រឹមត្រូវ គឺរូបរាង ឬទំហំដ៏ត្រឹមត្រូវ ។

សមូហភាព (Collectivité n.f. ou Corps composé) (អ. ថ. សៈ-មូ-ហៈ-ភាប) ន. (ម.- ភាវ ភាពនៃ(ការ ប្រជុំ, ភាពនៃការរួបរួម, ភាពនៃការប្រមូលផ្តុំ ។

អធិ. សមូហភាពនេះ < សមូហ «ការប្រជុំ, ពួក, បន, ក្រុម, គណៈ, ហ្វូង, ការរួបរួម, ការប្រមូល» + ភាព «ភាវៈ, បែបបទ, លំនាំ, ឫកពា . . .» បានដល់ភាពនៃការប្រមូលផ្តុំពួកគណៈ ឬ ភាពនៃការប្រមូលការរួបរួម ។

សម្ពោធ (Inaugurer v.t.) (អ. ថ. សំ.ពោត), កិ. (សំ. ម.) រំឭក, ថ្លែងសេចក្តីដោយច្បាស់លាស់, ពោលពាក្យប្រាស្រ័យរកគ្នា ។

អធិ. សម្ពោធនេះ បានដល់ការប្រើជា កិ. ជាធ្វើបុណ្យ ឬ ថ្លែងសេចក្តីរៀបរាប់ រាយការក្នុងទីប្រជុំធ្វើឬ ឡើងមន្ទីរថ្មី ជាដើម ឧទា. ពួកមហាជនសម្ពោធសាលាបាលីរង់មួយខ្នងដែលគេកសាងនៅវត្តកណ្ដាគារការាម ។

សម្ពោធន៍ ឬ ការសម្ពោធ (Inauguration n. f.) (អ. ថ. សំ–ពោត ឬ ការ–) ការរំឭក; ការថ្លែងសេចក្តីដោយច្បាស់លាស់, ការពោលពាក្យប្រាស្រ័យរកគ្នា, ការហៅរកគ្នាចំពោះមុខ ។

អធិ. សម្ពោធន៍ ឬ ការសម្ពោធនេះ បានដល់ការប្រើជា ន. ថា ពិធីធ្វើបុណ្យ ឬ ពាក្យពោលថ្លែងសេចក្តីរៀបរាប់ ឬរាយការក្នុងទីប្រជុំធ្វើ ឬ ឡើងមន្ទីរថ្មីជាដើម ឧទា. ការសម្ពោធធ្វើសាលាបាលីរង់នៅវត្តកណ្ដារការាម ជាពិធីមួយយ៉ាងឧឡារិកអធិកអធម៌ ។

សយនដ្ឋាន ( Portoir) n. m.) (អ. ថ. ស:- យ៉ :-

នុត៍-ឋាន) ន. (ម.; សំ. សយនស្ថាន) ទី ឬ កន្លែង សម្រាប់ដេក, កន្លែងសម្រាប់អាស្រ័យនៅ ។

អធិ. សយនដ្ឋាននេះ < សយន « ការដេក, ការនៅ អាស្រ័យ ...» + ឋាន « ទី, កន្លែង ...» បានដល់កន្លែង ឬ ផ្ទះសម្រាប់អាស្រ័យដេកនៅ មានកន្លែងសម្រាប់សំណាក់ ដេកនៅរៀនសូត្ររបស់កូនសិស្សជាដើម ។

សល្យកម្ម (Chirurgie n.f.) (អ. ថ. ស័ល-ល្យៈ ក័ម) ន. (ម.) អំពើរបស់បុគ្គលដែលចេះវៃឆ្លាស់, ការ ធ្វើរបស់បុគ្គលដែលឆ្លាតវាងវៃ ។

អធិ. សល្យកម្មនេះ < សល្យ « ឆ្លាតវាងវៃ, ចេះវៃឆ្លាស់, ប៉ិនប្រសប់ » + កម្ម « ការធ្វើ, អំពើ, កិច្ចការដែល គេត្រូវធ្វើ » បានដល់អំពើរបស់បុគ្គលដែលឆ្លាតវាងវៃ ឬ ប៉ិន ប្រសប់ ។

សល្យពេទ្យ (Chirurgien n.m.) (អ.ថ.ស័ល–ល្យៈ

ពែត ) ន. ( សំ. សល្យវៃទ្យ ; ម. សល្យវេជ្ជ ) ពេទ្យដែលឈ្លាសវាងវៃ; អ្នកចេះថ្នាំរម្ងាប់រោគដែលប៉ិនប្រសប់ ។

អធិ. សល្យពេទ្យនេះ < សល្យ « ដែលឆ្លាតវាងវៃ, ចៀវឆ្លាស់, ប៉ិនប្រសប់ » + ពេទ្យ «អ្នកចេះថ្នាំរម្ងាប់រោគ, គ្រូមើលជម្ងឺ..» បានដល់ពេទ្យប៉ិនប្រសប់ ឬ គ្រូមើលជម្ងឺដែលឈ្លាសវាងវៃ ស្ទាត់ជំនាញ ប៉ិនប្រសប់ក្នុងពិធីពេទ្យ ។ ពា. សល្យពេទ្យទន្តកម្ម ( Chirurgien dentiste )=គ្រូពេទ្យដែលប៉ិនប្រសប់ខាងកិច្ចថែរក្សាធ្មេញ ។

សល្យសាស្ត្រ (Chirurgie n.f.) ( អ.ថ. ស័ល–ល្យៈ–សាស ) ន. ( សំ. សល្យឝាស្ត្រ ; ម. សល្យសត្ថ ) គម្ពី ឬ វិជ្ជា ប្រាប់ខាងការប៉ិនប្រសប់ ។

អធិ. សល្យសាស្ត្រនេះ < សល្យ « ដែលឆ្លាតវាងវៃ ...» + សាស្ត្រ « គម្ពីរ , ក្បួន , តម្រា , វិជ្ជា ... » បានដល់គម្ពីរ ឬ ក្បួន , តម្រា , វិជ្ជា សម្រាប់រៀនសូត្រឲ្យចេះដឹងស្ទាត់

ជំនាញវាងវៃ ប៉ិនប្រសព្វ ។

សលាក (Etiquette n.f.) (អ. ថ. ស: -លា៉ -ក: ឬ ស: - លា៉ក ) ន. (សំ. ឝលាកា; ម. សលាកា) ស្លាក, សន្លឹកស្លាក ឬ សន្លឹកឆ្នោត ។

អធិ. សលាកនេះ បានដល់សន្លឹកស្លាកដែលគេសរសេរសម្រាប់ចាប់ ឬ សន្លឹកឆ្នោត ។

សលាកប័ត្រចល័ត (Fiche mobile) (អ. ថ. ស:-លា៉ -ក: -ប័ត -ច: -ល័ុត ) ន. (សំ. ម. ក្ល.) សន្លឹកស្លាកដែលកម្រើក ឬ ការញាប់ញ័រនៃសន្លឹកឆ្នោត ។

អធិ. សលាកប័ត្រចល័តនេះ < សលាក « ស្លាក, ឆ្នោត » + បត្រ « សន្លឹក , ក្រដាស , សំបុត្រ » + ចលត « ញាប់ញ័រ , កម្រើក , រំកើប , រំជួល , បះបោរ » បានដល់សន្លឹកស្លាក ឬ ក្រដាសឆ្នោតរបស់ក្រុមអ្នកជ្រួលជ្រើម ឬ អ្នកបះបោរ ពុំនោះបានដល់ការកម្រើករញ្ជួយនៃសន្លឹកស្លាក ។

សវនាការ (Audience n. f.) (អ. ថ. សៈ-វ៉ៈ-នា-កា) ន. (ម.; សំ. ស្រវណាការ) អាការស្តាប់, អាការឮ ។

អធិ. សវនាការនេះ < សវន «កិរិយាស្តាប់, ឮ» + អាការ «គ្រឿងសំគាល់, លក្ខណៈជាគ្រឿងសង្កេត, រូបរាង, កិច្ចការ, វិធី, លំនាំ, ឫកពា, កិរិយា, សភាព...» បានដល់អាការនៃកិរិយាស្តាប់ ឬ អាការនៃកិរិយាឮសូរសំឡេង សំដី ភាសា ១ពា. ព្រះរាជាទ្រង់ធ្វើសវនាការពាក្យរបស់មហាជនខ្លះទៅ ។

ស្វ័យគម (Robot n. m.) (អ. ថ. ស្វៃ-គំ) ន. (សំ. ស្វយគម; ម. សយគម) ដំណើរទៅដោយខ្លួនឯង ។

អធិ. ស្វ័យគមនេះ < ស្វយ «ខ្លួន, ខ្លួនឯង» + គម «ទៅ, ដល់» បានដល់ការទៅដោយខ្លួនឯង ឬ ដំណើរដល់ដោយខ្លួនឯង ។

ស្វយ័ត (Autonome adj.) (អ. ថ. ស្វៈ-យ៉ុត) គុ.

(សំ. ស្វយត) ដែលកើតខ្លួនឯង, ដែលធ្វើអ្វីបានខ្លួនឯង ។

អធិ. ស្វ័យតនេះ បានដល់ការប្រើជា គុ. ថា : ដែលកើតខ្លួនឯង , ដែលសម្រេចកិច្ចការអ្វីដោយខ្លួនឯង , ដែលប្រព្រឹត្តទៅបានខ្លួនឯង ។

ស្វ័យត្រាណ (Auto-défense) (ម. ថ. ស្វៃត្រាណ) ន. សំ. ស្វយត្រាណ; ម. សយតាណ) ការគ្រប់គ្រងខ្លួនឯង ការពឹងពាក់អាស្រ័យដោយខ្លួនឯង ។

អធិ. ស្វ័យត្រាណនេះ < ស្វយ «ខ្លួន, ខ្លួនឯង» + ត្រាណ «ការគ្រប់គ្រង, រក្សា, ទីពំនាក់, ទីពឹង» បានដល់ ការពឹងពាក់អាស្រ័យដោយខ្លួនឯង ឬ សំដៅយកកងរក្សាខេត្រ មួយក្រុមដោយឡែកដែលមានយាមល្បាតតាមប៉ម (ប៉ុកកូស= (Blockhaus) ឬ ស្ថានទីផ្លូវគមនាគមន៍ ។

ស្វ័យប្រវត្តិ (Automatique adj.) (អ. ថ. ស្វៃ– ប្រ– វ័ត) គុ. (សំ. ស្វយប្រវត្ត; ម. សយបវត្ត) ដែលប្រព្រឹត្ត

ទៅដោយខ្លួនឯង, ដែលធ្វើដោយខ្លួនឯង ។

អធិ. ស្វ័យប្រវត្តនេះ < ស្វយ "ខ្លួន, ខ្លួនឯង" + ប្រវត្ត "ដែលប្រព្រឹត្តទៅ, ដែលធ្វើតាម, ដែលប្រព្រឹត្តវៀនមក" បានដល់គ្រឿងប្រដាប់ដែលប្រព្រឹត្តទៅបានដោយខ្លួនឯង ហាក់ដូចជារបស់ដែលមានវិញ្ញាណ ។ ដោយស្វ័យប្រវត្ត (Automatiquement adv.)

ស្វ័យភាព (Autonomie n. f.) (អ. ជ. ស្វៃ. -ភាប)

ន. (សំ. ស្វយភាវ; ម. សយភាវ.) ភាពនៃខ្លួនឯង, ភាពនៃកិច្ចការដែលកើតដោយខ្លួនឯង ។

អធិ. ស្វ័យភាពនេះ < ស្វយ "ខ្លួន, ខ្លួនឯង" + ភាព "ការ, ; បែបបទ, លំនាំ, បុគល ..." បានដល់ភាពនៃកិច្ចការផ្សេងៗ ដែលសម្រេចដោយខ្លួនឯង ឬ ភាពនៃគ្រឿងប្រដាប់ផ្សេងៗ ដែលប្រព្រឹត្តទៅបានដោយខ្លួនឯង ។ ឧ. ស្វ័យភាពហិរញ្ញវត្ថុ (Autonomie financière) ។ល។

សហករណ៍ (Coopérative) (អ. ប. ស.– ហៈ–ក) ន. (សំ. ម. – ករណ) ការងារដែលរួមគ្នាធ្វើ, ដំណើររួមគំនិតគ្នាធ្វើការ, អំពើដែលធ្វើជាមួយគ្នា ។

អធិ. សហករណ៍នេះ < សហ «មួយអន្លើ, ព្រមទាំង, ជាមួយគ្នា, ដំណាលគ្នា» + ករណ "កិរិយាធ្វើ, ដំណើរធ្វើ» បានដល់កិរិយាធ្វើជាមួយគ្នា ឬ ដំណើររួមគំនិតគ្នាធ្វើការខាងឧស្សាហកម្ម ឬ ពាណិជ្ជកម្ម ឧទា. សហករណ៍នៃគ្រឿងឧបភោគបរិភោគ (Coopérative de consommation) ។ល។ ឃ. គ. ប. ។

សហការ (Collaboration n.f.) (អ.ប.ស:-ហៈ-កា) ន. (សំ.ម.) ការធ្វើជាមួយគ្នា, ការរួមធ្វើជាមួយគ្នា ។

អធិ. សហការនេះ < សហ «មួយអន្លើ...» + ការ «ធ្វើ, ការប្រើគេឲ្យធ្វើ» បានដល់ការធ្វើជាមួយគ្នា ឬ

ការដែលប្រមូលធ្វើជាមួយគ្នា ។

សហការី ( Collaborateur ) ( អ.ថ.សៈ-ហៈ- កា-រី ) ន. ( សំ. ម. ) អ្នកធ្វើការជាមួយគ្នា, អ្នកញុំាងការងារឲ្យកើតជាមួយគ្នា ។

អធិ. សហការីនេះ < សហ « មួយអន្លើ » + ការី « ជនអ្នកធ្វើ » បានដល់ជនអ្នកធ្វើការជាមួយគ្នា ឬ ជនអ្នករួបរួមប្រមូលគ្នាធ្វើការអ្វីមួយ ។

សហក្រុម ( Service commun ) ( អ. ថ. សៈ-ហៈ - ក្រុំ ) ន. ( សំ. សហក្រម ; ម. សហកម ) ពួកដែលរួមគ្នា, បក្សពួកជាមួយគ្នា ។

អធិ. សហក្រុមនេះ < សហ « មួយអន្លើ » + ក្រុម « លំដាប់, ពួក, បទ, គណៈ, ហ្វូង » បានដល់ពួកដែលរួបរួមជាមួយគ្នា ឬ បទដែលរួបរួមការងារជាមួយគ្នា ។

សហគត (Communautaire adj.) (អ. ឋ. សះ–ហៈ – គត់) គុ. (ម.) ដែលទៅជាមួយ, ដែលដល់ព្រមគ្នា ។

អធិ. សហគតនេះ < សហ « មួយអន្លើ » + គត « ទៅ, ដល់ » បានដល់ដំណើរដែលទៅព្រមគ្នា ឬ ដែលដល់ដំណាលគ្នា ។

សហគមន៍ (Communauté n.f.) (អ. ឋ. សះ–ហៈ – គំ) ន. (ម. – គមន) ការទៅជាមួយគ្នា, ដំណើរទៅព្រមគ្នា ។

អធិ. សហគមន៍នេះ < សហ «មួយអន្លើ...» + គមន កិរិយាទៅ, ដល់ » បានដល់ដំណើរទៅព្រមគ្នា ឬ ការដល់ដំណាលគ្នា ( សំដៅយក.ដំនុំសង្ឃក៏បាន ) ។

សហគ្រាស (Entreprise n.f.) (អ. ឋ. សះ–ហៈ –) ន. (សំ. ; ម. សហគាហ) ការចាប់យកព្រមគ្នា,

ដំណើរកាន់យកដំណាលគ្នា , ការងាររបស់សហគ្រិន , ករណីយកិច្ចដែលសហគ្រិនត្រូវប្រកបធ្វើ ។

អធិ. សហគ្រាសនេះ < សហ «មួយអន្លើ» + គ្រាស «កិរិយាចាប់, ការចាប់យក, បានដល់ការចាប់យកព្រមគ្នា ឬ ដំណើរកាន់យកជាមួយគ្នា គឺសំដៅយកកិច្ចានុកិច្ចរបស់សហគ្រិនត្រូវប្រកបធ្វើ ។

សហគ្រិន (Entrepreneur n.m.) (អ. ថ. សះ-ហះ-) ន. (សំ.) អ្នកទទួលការ, អ្នកទទួលម៉ៅការ ។

អធិ. សហគ្រិននេះ បានដល់អ្នកទទួលម៉ៅការ ឬ អ្នកឈរឈ្មោះទទួលម៉ៅការគ្រប់យ៉ាង ។

សហជីព ( Syndicat n.m. ) (អ. ថ. សះ - ហះ - ជីប) ន. (សំ. ម.-ជីវ) ជីវិតរួមគ្នា, ការរស់នៅរួមគ្នា, ការចិញ្ចឹមជីវិតជាមួយគ្នា ។

អធិ. សហជីពនេះ < សហ «មួយអន្លើ» + ជីព

„ជីវិត, ការរស់នៅ, ការចិញ្ចឹមជីវិត„ បានដល់ការចិញ្ចឹមជីវិតជាមួយគ្នាឬ ជីវិតដែលរស់នៅជាមួយគ្នា ។

សហជីវិន (Compagnon) (អ. ជ. សៈ-ហៈ-) ន. (សំ. ម.,) អ្នកដែលរស់នៅជាមួយគ្នា, អ្នកដែលមានជីវិតរស់នៅរួមគ្នា ។

អធិ. សហជីវិននេះ < សហ « មួយអន្លើ » + ជីវិន « អ្នកដែលមានជីវិត, អ្នកដែលរស់នៅ » បានដល់មនុស្សដែលមានជីវិតរស់នៅដោយការរួមគ្នា ឬ អ្នកដែលមានការចិញ្ចឹមជីវិតរួមជាមួយគ្នា ។

សហជីវិនី (Compagne) (អ.ជ.សៈ-ហៈ-) ន. (សំ. ម.) ស្ត្រីដែលរស់នៅជាមួយគ្នា ឬ ដែលមានការចិញ្ចឹមជីវិតជាមួយគ្នា ។

អធិ. សហជីវិនីនេះ < សហ « មួយអន្លើ » + ជីវិនី « អ្នកដែលមានជីវិត, អ្នកដែលរស់នៅ » បានដល់

ស្រីដែលមានជីវិតរស់នៅជាមួយគ្នា ឬ ដែលមានការចិញ្ចឹមជីវិតរួមគ្នា ។

សហធម្មិក (Clergé) (អ.ថ. ស:–ហ:–ធ័ម–ម៉ិក) ន· (សំ. ម·) អ្នកប្រព្រឹត្តធម៌ត្រូវគ្នា , អ្នកប្រព្រឹត្តធម៌ដូចគ្នា ។

អធ. សហធម្មិកនេះ < សហ « មួយអន្លើ » + ធម្មិក « អ្នកប្រព្រឹត្តធម៌ , អ្នកប្រកបដោយធម៌ » បានដល់អ្នកប្រព្រឹត្តធម៌ត្រូវគ្នា ឬ បព្វជិតដែលជាអ្នកប្រព្រឹត្តធម៌ត្រូវគ្នា , ប្រព្រឹត្តវិន័យត្រូវគ្នា ( ព. ពុ. ) : ភិក្ខុ , ភិក្ខុនី , សាមណេរ, សាមណេរី , សិក្ខមានា ទាំង ៥ ពួកនេះ ហៅថា សហធម្មិក ។

សហប្រតិបត្តិការ (Coopération n.f.) (អ. ថ. ស:–ហ:–ប្រ:–តិ–ប័ត–កា) ន. (សំ. ; ម. សហបដិបត្តិការ) ការប្រតិបត្តិជាមួយគ្នា, ប្រតិបត្តិការរួមគ្នា , ប្រព្រឹត្ត

ការរួមគ្នា ។

អធិ. សហប្រតិបត្តិការនេះ < សហ « មួយអន្លើ » + ប្រតិបត្តិ « ប្រព្រឹត្ត, កាន់, ធ្វើតាម » + ការ « ធ្វើ » បាន ដល់ប្រតិបត្តិការរួមជាមួយគ្នា ឬ ការប្រព្រឹត្តិធ្វើរួមជាមួយគ្នា ។

សហព័ទ្ធ ( Conjoint n.m. ) ( អ. ច. សៈ – ហៈ- ព័ត ) ន. ( ម. – ពទ្ធ ) ការចងភ្ជាប់គ្នា, ការរួបរួមតភ្ជាប់គ្នា ។

អធិ. សហព័ទ្ធនេះ < សហ « មួយអន្លើ » + ពទ្ធ, « ការចង, ការជាប់, ការជាប់ជំពាក់ » បានដល់ការជាប់ទាក់ ទងជាមួយគ្នា ឬ ការរួបរួមគំនិតជាមួយគ្នារវាងស្វាមីឬភរិយា ។

សហព័ន្ធ ( Fédération n.f. ) ( អ. ច. សៈ – ហៈ – ពាន់ ) ន. ( សំ. ម. – ពន្ធ ) ការចងរួមគ្នា, ការចង ភ្ជាប់ជាមួយគ្នា ។

អធិ. សហព័ន្ធនេះ < សហ « មួយអន្លើ... » + ពន្ធ « ចំណង, ការចង, ការចងទាក់គ្នា, ការជាប់ជំពាក់ » បាន

ដល់ការចងភ្ជាប់គ្នា ឬ ការចងភ្ជាប់ទាក់ទងជាមួយគ្នា ។

សហភគិនី ( Consœur ) ( អ. ថ. សៈ- ហៈ- ភៈ - ) ន. ( ម. ; សំ. សហភគ្គិ ) បង-ប្អូនស្រីដែលរួមជាមួយគ្នា , បងប្អូនស្រីដែលកើតជាមួយគ្នា ។

អធិ. សហភគិនីនេះ < សហ «មួយអន្លើ...» + ភគិនី «បង-ប្អូនស្រី» បានដល់បង-ប្អូនស្រីដែលកើតអំពីផ្ទៃមាតាជាមួយគ្នា គឺបង-ប្អូនស្រីដែលរួមឧទរជាមួយគ្នា ( ពាក្យនេះច្រើនប្រើជាកវិសព្ទ ) ។ ឃ. គ. ប. ។

សហភាព ( Union n.f. ) ( អ. ថ. សៈ- ហៈ- ភាប ) ន. ( សំ. ម. - ភាវ ) ភាពនៃការរួមគ្នា , ភាពនៃការរួមជាមួយគ្នា ។

អធិ. សហភាពនេះ < សហ « មួយអន្លើ » + ភាព « ភាវៈ , បែបបទ , លំនាំ , ឫកពា... » បានដល់ភាពនៃស្រុកទេសដែលរួមជាមួយគ្នា គឺស្រុកទេស

ដែលជាប់ទាក់ទងកិច្ចការជាមួយគ្នា ។ ឧ. សហភាពបារាំង (Union Française) ។ សហភាពគយ (Union douanière) ។ល។ ឃ. គ. ប. ។

សហភោជនដ្ឋាន (Mess n.m) (អ. ថ. ហៈ-ភោ-ជៈ-នុត-ឋាន) ន. (ម.) កន្លែងសម្រាប់បរិភោគភោជនជាមួយគ្នា, ទីសម្រាប់រួបរួមភោជនជាមួយគ្នា ។

អធិ. សហភោជនដ្ឋាននេះ < សហ «មួយអន្លើ» + ភោជន «វត្ថុសម្រាប់បរិភោគ, អាហារ» + ឋាន «ទី, កន្លែង ទីតាំង, ទីដំកល់» បានដល់កន្លែងបរិភោគអាហាររួមគ្នា ឬ ទីកន្លែងសម្រាប់ធ្វើអាហារបរិភោគរួមជាមួយគ្នា ។ ឧ. សហភោជនដ្ឋាននាយទាហាន (Mess officiers) ។

សហលក្ខន្តិកៈ (Statut commun) (អ. ថ. សៈ-ហៈ-ល័ក-ខ័ន-តិ-កៈ) ន. (ម. សំ.) លក្ខន្តិកៈរួមគ្នា, សេចក្តីកំណត់ដែលជាប់ស្រេចជាមួយគ្នា ។

អធិ. សហលក្ខន្តិកៈនេះ < សហ « មួយអន្លើ » + លក្ខន្តិកៈ «សេចក្ដីកំណត់ដែលមានក្ទុ៍ទីបំផុត , សេចក្ដីកំណត់ដាច់ស្រេច , លក្ខណៈច្បាប់សម្រាប់សមាគម ឬ ក្រុម-ហ៊ុន » បានដល់លក្ខន្តិកៈដែលរួមជាមួយគ្នា ឬ លក្ខណៈច្បាប់ដែលមាន ១ មាត្រាសម្រាប់សមាគមដែលរួមជាមួយគ្នា ។

សហសេវិក (Collègue) (អ. ថ. សៈ – ហៈ – សេ – វិក) ន. (សំ. ម.) អ្នកបម្រើជាមួយគ្នា , អ្នករួមការបម្រើជាមួយគ្នា ។

អធិ. សហសេវិកនេះ < សហ « មួយអន្លើ » + សេវិក «អ្នកបម្រើ , អ្នកចាំទទួលការបម្រើ , អ្នកគាល់បម្រើ , បរិវារ » បានដល់ពួកជនអ្នកបម្រើជាមួយគ្នា ឬ ជនអ្នករួមគ្នារង់ចាំទទួលការបម្រើ ។

សហឧត្តមគតិ (Idéal commun) (អ. ថ. សៈ – ហៈ – អ៊ុត – ដំ – មៈ – គៈ – តិ) ន. (ម.) ឧត្តមគតិរួមគ្នា,

គតិយាន៍ខ្ពង់ខ្ពស់ដែលរួមចូលគ្នា ។

អធិ. សហឧត្តមគតិនេះ (សហ «មួយអន្លើ» + ឧត្តម «ខ្ពង់ខ្ពស់, កន្ទង់, ល្អ, ប្រសើរ, ថ្លៃថ្នូ, បរិបូណ៌, សម្បូណ៌» + គតិ «ដំណើរ, លំនាំ, សមសារ» បានដល់ឧត្តមគតិដែលរួមជាមួយគ្នា ឬ គតិយាន៍ខ្ពង់ខ្ពស់របស់អ្នកដែលរួមគំនិតជាមួយគ្នា ។

សាកល (Universel adj) (អ. ថ. -កល់) គុ. (សំ. ម. សកល) ដែលទូទៅ, ដែលសាធារណ៍, ទាំងអស់, ទាំងគ្រប់, ទាំងមូល ។

អធិ. សាកលនេះ សម្រាប់ប្រើជា គុ. ដែលសំដៅសេចក្តីថា ដែលធារណៈទូទៅ មិនកំណត់ចំពោះមុខមួយ ៗ (ចូលមើលពាក្យសកលផង) ។

សាជីវកម្ម (Corporation n.f.) (អ. ថ. សា-ជី-វៈ

កម្ម ) ន. ( ម. ) ការចិញ្ចឹមជីវិតរួមគ្នា , ដំណើរធ្វើការរបរចិញ្ចឹមជីវិតជាមួយគ្នា , ការរស់នៅដោយខ្លួនឯង ។

អធិ. សាជីវកម្មនេះ < សហ > សា « រួម , រួមគ្នា , ព្រមទាំង , ជាមួយគ្នា , មួយអន្លើ » + អាជីវកម្ម « អំពើនៃការរស់នៅ , កិច្ចការដែលគេធ្វើចិញ្ចឹមជីវិត» « បានដល់កិច្ចការដែលគេធ្វើដើម្បីចិញ្ចឹមជីវិតរួមគ្នា អាជីវកម្មដែលរួមជាមួយគ្នា ១៣. សាជីវកម្មខ្មែរ ( Corporation khmère ) ។

សាធារណការ (Travux publics) (អ. ថ. សា-ធា-រៈ-ណៈ-កា) ន. (ម.) ការងារទូទៅ, ការងារដែលត្រូវធ្វើទូទៅដើម្បីជាប្រយោជន៍ដល់ជនផង ។

អធិ. សាធារណការនេះ < សាធារណ "ទូទៅ , ទាំងអស់ , ទាំងមូល, ទាំងស្រុង " + ការ "ធ្វើ" បានដល់ការងារទូទៅ គឺការងារដែលគេត្រូវធ្វើដើម្បីជាប្រយោជន៍ដល់ជនទូទៅ មានធ្វើថ្នល់, សង់ស្ពានជាដើម ។

**សាធារណជន** (Puplic n. m.) (អ. ថ. សា–ធា–រ:–ណ:ជន់) ន.(ម.) ជនទូទៅ, ប្រជាជនទូទៅ, ជនសាធារណ៍ ។

អធិ. សាធារណជននេះ < សាធារណ "ទូទៅ" + ជន "សព្វសត្វដែលកើតក្នុងលោក, មនុស្ស, អ្នកផង៉" បានដល់ប្រជាជនទូទៅ ឬ ពួកមនុស្សដែលកើតក្នុងលោកទាំងអស់ ។

**សាធារណរដ្ឋ** (Répuplique n.f.) (អ. ថ. សា–ធា–រ:–ណ:រ័ត) ន.(ម.) រដ្ឋទូទៅ, ប្រទេសទាំងអស់, ទាំងមូល ។

អធិ. សាធារណរដ្ឋនេះ < សាធារណ "ទូទៅ" + រដ្ឋ "ដែន, ប្រទេស, អ្នកនៅក្នុងដែន, រាស្ត្រ, ប្រជាជន" បានដល់ដែនឬប្រទេសទាំងមូល ដែលគ្មានព្រះរាជាជាប្រមុខ មានតែពួកប្រជាជនទូទៅ រើសតំណាងម្នាក់ស្ដីទីជាប្រមុខរដ្ឋ ហៅថា

ប្រធានាធិបតី ជាអ្នកត្រួតត្រាកិច្ចការផែនដីក្នុងប្រទេសទីងខាងក្រៅប្រទេស ។ល។ សាធារណរដ្ឋបារាំង (République Française) ។ល។

សាធារណសិក្សា (Instruction publique) (អ. ថ. សា-ធា-រៈ-ណៈ-សិក-សា) ន. (សំ. ; ម.- សិក្ខា) ការរៀនសូត្រទូទៅ, ការរៀនសូត្រជាសាម័ញ្ញ ។

អធិ. សាធារណសិក្សានេះ < សាធារណ «ដែលទូទៅ, ដែលទុកជាកណ្ដាល, ដែលមិនចំពោះតែមួយៗ ...» + សិក្សា «ការរៀន ការរៀនទន្ទេញ, ការសូត្ររៀន, ការហ្វឹក, ការហ្វឹកហាត់, ការប្រុងប្រយ័ត្នរក្សាមារយាទឲ្យល្អ ...» បានដល់ការរៀនសូត្រទូទៅមិនចំពោះវណ្ណៈ ឬ ចំណោះតែមួយមុខៗ ។

សាធារណសេរីភាព (Liberté publique) (អ. ថ. សា-ធា រៈ- ណៈ- សេ- រ៊ី- ភាប ) ន. (ម.- ភាវ ) ភាពនៃអំណាចដែលអាចធ្វើអ្វីបានតាមអំពើចិត្តទូទៅ ,

ភាពនៃសិទ្ធិដែលមានអំណាចទូទៅលើខ្លួន ។

អធិ. សាធារណសេរីភាពនេះ < សាធារណ "ដែលទូទៅ, ដែលប្រើបានទាំងអស់គ្នា, ដែលមិនចំពោះតែមួយ ៗ, សាមញ្ញ, ដែលរាប់រយករាប់ពាន់" + សេរីភាព "ភាពនៃអំណាចលើខ្លួន, ភាពនៃអំណាចដែលអាចធ្វើអ្វីបានតាមចិត្ត, ភាពនៃអំណាចពេញទីដែលមានមាត្រាច្បាប់ជាគោល" បានដល់ភាពនៃអំណាចដែលអាចធ្វើអ្វីផ្សេងៗ បានទូទៅ តាមអំពើចិត្តរបស់ខ្លួន ឬ សេរីភាពក្នុងកិច្ចការគ្រប់យ៉ាងទូទៅ ។

**សាមញ្ញ** (Simple adj) (អ. ថ. សា–ម៉ុញ) គុ. (ម. ; សំ. សាមាន្យ) សាធារណៈ, ដែលជាធម្មតា, ដែលជាប្រក្រតី, ដែលស្មើៗគ្នា ។

អធិ. សាមញ្ញនេះ ប្រើជា គុ. តាមភាសាបារាំង ប្រែថា ដែលជាធម្មតា, ដែលដូចប្រក្រតី, ដែលសាធារណ៍ ឧទា. ពាក្យសាមញ្ញ ពាក្យផ្សារ ។ មនុស្សសាមញ្ញ មនុស្ស

សាធារណៈ, មនុស្សរយ ៗ របស់សាមញ្ញ របស់រយ ៗ

សាមន្តរាជ (Vassal n. f.) (អ. ថ. សា – ម៉ន់ – តៈ – រាច) ន. (ម. ព្រះរាជាក្នុងប្រទេសជិតខាង, ប្រទេសរាជ (ស្តេចចំណុះគេ)ៗ

អធិ. សាមន្តរាជនេះ < សាមន្ត "ជុំវិញ . . ." + រាជ "ស្តេច" បានដល់ស្តេចដែលនៅក្នុងប្រទេសជិតខាង ឬ ស្តេចដែលជាចំណុះគេ (ប្រទេសរាជ) ៗ

សាមីជនខណ្ឌប័ណ្ណ (Titulaire du livret à coupons) (អ. ថ. សា – មុី – ជន់ – ខ័ន – ឌៈ – ប័ន) ន. (ម.– បណ្ណ) ប័ណ្ណដែលមានកម្រិតរបស់ជនជាម្ចាស់, សំបុត្រ ឬ លិខិតដែលមានកំណត់របស់ជនសាមីរូប ៗ

អធិ. សាមីជនខណ្ឌបណ្ណនេះ < សាមី "ម្ចាស់ ...." + ជន "សព្វសត្វដែលកើតក្នុងលោក, មនុស្ស, អ្នកផង" + ខណ្ឌ "កម្រិត, កំណត់, ប៉ែក, សង្កាត់" + បណ្ណ "សន្លឹក,

ក្រដាស់, សំបុត្រ, លិខិត" បានដល់ខណ្ឌបណ្ណជនជាម្ចាស់ខ្លួន គឺសំបុត្រកម្រិតថ្នាក់របស់ជនជាសាមីខ្លួន ។

ស្វាមីភរិយា (Epoux n.m.pl.) អ.ថ. ស្វា–មី–ភៈ–រិ–យា) ន. (សំ. ស្វាមិនភាយា; ម. សាមិភរិយា) ប្ដីប្រពន្ធ, ប្ដូនឹប្រពន្ធ ។

អធិ. ស្វាមីភរិយានេះ < ស្វាមី "ម្ចាស់, ប្ដី" + ភរិយា "ស្ត្រីដែលស្វាមីត្រូវចិញ្ចឹម, ប្រពន្ធ" បានដល់ស្ត្រីដែលស្វាមីត្រូវចិញ្ចឹម គឺប្ដូនឹប្រពន្ធ ។

សារ (Lettre n.f. ou Message n.m.) (អ. ថ. សា) ន. (សំ. ម.) សំបុត្រ, លិខិត ឬសេចក្ដីសំខាន់ ។

អធិ. សារនេះ ប្រែថា "ខ្លឹម, សេចក្ដីខ្ជាប់ខ្ជួន, មាំមួន, រឹងប៉ឹង, ការសំខាន់, របស់សំខាន់, គោល, គោលចារិក, ឡាក់ហាន, កម្លាំង, អំណាច, សេចក្ដីអង់អាច, សេចក្ដីក្លាហាន, សំណាង, បុណ្យភ័ក្ត្រ, តម្លៃ, ទ្រព្យ, សម្បត្តិ,

របស់សុទ្ធ , សេចក្តីពិត , ប្រយោជន៍ , ផលប្រយោជន៍ , ធាតុសុទ្ធ ឬ ធាតុផ្សំណាមួយ, ពាក្យសង្ខេប, ពាក្យបំប្រួញ...» ។ សារ ក្នុងទីនេះ ប្រែថា « Lettre » ឧ.ទា. សារអនុលោម ( Lettre d'agrément ) = សារដែលប្រមុខរដ្ឋ ឆ្លើយថាយល់ព្រមឲ្យតាំងទូតបរទេស ។ សារតាំង ( Lettre de créance ) = សារដែលប្រមុខរដ្ឋចេញឲ្យទូតកាន់ទៅ ប្រគល់ចំពោះប្រមុខរដ្ឋបរទេស ។ សារឱកាសទាន ( Lettre d'exéquature ) = សារដែលប្រមុខរដ្ឋ បើកឱកាសឲ្យកុងស៊ុលបរទេសបំពេញមុខការនាទី ។ សារ ដែលប្រែថា « Message » ឧ.ទា. ព្រះរាជសារ ( Message Royal ) = លិខិតព្រះរាជា ឬ ចុកហ្វាយ ។ល។

សារការី ( Notaire n.m. ) ( ស. ឋ. សា – រ: – កា – រី ឬ សា – កា – រី ) ន. ( ម. ) អ្នកធ្វើសារ , អ្នកធ្វើគ្រឿងចំណាំ ។

អធិ. សារការនេះ < សារ « សំបុត្រ , គោលបារគ , ឡាក់ប៉ាន , អំណាច , តម្លៃ, ផលប្រយោជន៍ , . . . » + ការ « អ្នកធ្វើ , ជនអ្នកធ្វើ » បានដល់ជនអ្នកធ្វើសារ គឺជនអ្នកធ្វើគោលបារគជាគ្រឿងចំណាំ ។

សារណា (Mémoire n. f.) (អ. ថ. សា-រ:-) ន. (ម.) ទីពឹង , ពំនាក់ , ការរឭក, ទីជ្រកអាស្រ័យ ។

អធិ. សារណានេះ បានដល់ការពឹងពាក់អាស្រ័យ ឬរបស់សុទ្ធ សេចក្តីពិតសំខាន់ ជាគ្រឿងពំនឹងពំនាក់ ។

សារប្រយោជន៍ (Bien) (អ. ថ. សា-រ:-ប្រ-យោ-ច) ន. (សំ.-ប្រយោជន ; ម. សារបយោជន) ប្រយោជន៍សំខាន់, ប្រយោជន៍ប្រសើរ ឬ ថ្លៃថ្លា ។

អធិ. សារប្រយោជន៍នេះ < សារ « ដែលរឹងប៉ឹង, ខ្ជាប់ខ្ជួន, មាំមួន, មានតម្លៃ, ថ្លៃថ្លា , ប្រសើរ, ខ្ពង់ខ្ពស់ , សំខាន់, គ្រប់សព្វ . . . » + ប្រយោជន៍ « ដំណើរ

ដែលគួរប្រកប, អ្វីៗដែលគេត្រូវការ..» បានដល់ប្រយោជន៍ដ៏មាំមួនខ្ជាប់ខ្ជួន ឬ របស់អ្វីៗដែលគេត្រូវការ ឧទា. សារប្រយោជន៍របស់ប្រជារាស្ត្រ (Bien du peuple) ។

សារពត៌មាន (journal n. m.) (អ. ថ. សា-ព័រ-ដ-មាន) ន. (សំ. សារវត៌មាន; ម. សារវត្តមាន) ដំណើរដែលប្រព្រឹត្តទៅ, រឿងរ៉ាវកំពុងប្រព្រឹត្តទៅ; កាសែត ។

អធិ. សារពត៌មាននេះ < សារ "សំបុត្រ, ខ្លឹម, សេចក្ដីសំខាន់, រឿងរ៉ាវ...» + ពត៌មាន "ដំណើរកំពុងប្រព្រឹត្តទៅ, ដំណើរកំពុងមានចំពោះមុខ» បានដល់កាសែតដែលផ្សាយដំណើរផ្សេងៗក្នុងប្រទេសនីមួយៗ ឧទា. សារពត៌មានកម្ពុជា (journal du Cambodge) ។ល។

សារពើពន្ធ (Fiscalité n. f.) (អ. ថ. សា-រ-ពើ-ពន់) ន. (សំ. ម. ក្ង.) ពន្ធគ្រប់យ៉ាង, អាករទូទៅ ។

អធិ. សារពើពន្ធនេះ < សំស្ក្រឹតថា សវ៌, បុ. ពហុ.

សរើ, រ > ព = សពើ; ម. សព្វ, បុ. ពហុ. សព្វេ > សារពើ "ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, ទាំងគ្រប់, គ្រប់, គ្រប់សព្វ, សព្វគ្រប់, គ្រប់យ៉ាង, ទូទៅ, រាល់" + ពន្ធ "សួយ, អាករ ដែលប្រជាជនត្រូវបង់តាមកំណត់" បានដល់ពន្ធដែលគេត្រូវបង់គ្រប់មុខ ឬអាករដែលប្រជាជនត្រូវបង់ជូនរដ្ឋាភិបាលទូទៅ ។

សារីរវេច្ឆេទនសាស្ត្រ (Anatomie n.f.) (អ. ថ. សា-រី-រវ៉េ- ឆេ-ទៈ-នៈ-សាស) ន. (សំ. -ឝាស្ត្រ; ម. សារីរវេច្ឆេទនសត្ថ) ក្បួនឬវិជ្ជា ខាងការវះកាត់សរីរៈរាងកាយ

អធិ. សារីរវេច្ឆេទនសាស្ត្រនេះ < សារីរវេច្ឆេទន "ការកាត់សរីរៈ, ការកាត់ផ្តាច់រាងកាយ" + សាស្ត្រ "គម្ពីរ, ក្បួនឬតម្រា, វិជ្ជា ..." បានដល់គម្ពីរ, ក្បួន តម្រា, វិជ្ជា សម្រាប់កាត់វះសរីរៈមនុស្សសត្វ ឬ សម្រាប់រៀនកាត់សរីរៈរូបរាងកាយរបស់មនុស្សសត្វ ។

សារលិខិត ( Acte n.f. ) (អ. ថ. សា–រ:– ឬសា–លិ– ) ន. ( ម. ) សំបុត្រដ៏សំខាន់, សំបុត្រដែលមានគោល ។

អធិ. សារលិខិតនេះ < សារ « ដែលរឹងបុឹង, ខ្លាប់ខ្លួន, មាំមួន, ប្រសើរ, ខ្ពង់ខ្ពស់, ថ្លៃថ្លា, មានតម្លៃ, មានផលប្រយោជន៍ ... » + លិខិត « សំបុត្រ, ពាក្យ, សេចក្ដីសរសេរ ... » បានដល់លិខិតដែលមានសារ: គឺសំបុត្រដែលមានឡាក់ហាន់គោលចារឹកដ៏ខ្លាប់ខ្លួន ឧទា. សារលិខិតព្យាបាលភាព (Acte du tutelle) ។ សារលិខិតពេញច្បាប់ (Acte légalisé) សារលិខិតលក់ (Acte de vente)

សារ័ទ្ធ (Essentiel adj.) (អ. ថ. សា–រ:–រ័ទ) គុ. (ម. សារវន្ត) ដែលមានខ្លឹម, ដែលមានប្រយោជន៍, ដែលថ្លៃថ្លា ។

អធិ. សារ័ទ្ធនេះ សម្រាប់ប្រើជា គុ. ថា: ដែលមាំមួន, ដែលប្រសើរ, ខ្ពង់ខ្ពស់ ..., បើស្រីជា សារទ្ធី ។

សារាចរ (Circulaire) (ក. ថ. សា-រ៉ា-ច) ន. (ម.) ការប្រព្រឹត្តទៅនៃរឿងរ៉ាវ; សំបុត្រប្រាប់ដំណឹង ។

អធិ. សារាចរនេះ < សារ «សំបុត្រ, លិខិត, រឿងរ៉ាវ, ដំណឹង...» + ចរ «ការប្រព្រឹត្តទៅ, ដំណើរត្រាច់ទៅ» បានដល់សំបុត្រមួយបែបដែលរាជរដ្ឋាភិបាលប្រាប់ជាដំណឹងទូទៅដល់ជនគ្រប់រូបក្នុងព្រះរាជអាណាចក្រឲ្យឮ អំពីរឿងរ៉ាវអ្វីមួយដែលកើតឡើង ។ (ម. ព. បរាបរណ៍ភាគទី ១ ផង) ។

សាល (Salle) ន. (ពាក្យប្រើក្លាយមកពី ម. សាលា; សំ. គាលា) សាលា, រោង, ផ្ទះ, មន្ទីរ ។

អធិ. សាលនេះ បានដល់ពាក្យខ្មែរសម័យពីដើមហៅចំពោះតែ «សាលាជំនុំក្តី» ។ សម័យសព្វថ្ងៃនេះហៅពាក្យនេះបានច្រើនបែប ដូចជា សាលផែនទី (Salle des Cartes) ។ សាលរង់ចាំ (Salle d'attente) សាលទណ្ឌកម្ម (Salle de concierge) ។ សាលសន្និសីទ

(Salle des conférences) ។ សាលសាស្ត្រាចារ្យ (Salle des professeurs) ។ល។

សាលតន្ត្រី (Music-hall n.m.) (អ. ថ. សា-ល័ះ-តន់ ត្រី ឬ-ដន់-ត្រី) ន. (សំ. ឝាលាតន្ត្រិន៑; ម. សាលាតន្តី) រោងភ្លេង; រោងល្ខោន ។

អធិ. សាលតន្ត្រីនេះ < សាល «សាលា» + តន្ត្រី «ភ្លេងមានខ្សែ, គ្រឿងភ្លេងខ្សែ, គ្រឿងភ្លេងដេញដំផ្លុំគក» បានដល់រោងភ្លេងខ្សែ ឬ រោងល្ខោន ។

សាលយុទ្ធតុលាការ (Cour martial) (អ.ថ.សា-ល័ះ-យុត-តុ-លា-) ន. (ម.) សាលាតុលាការខាងសឹក, សាលាជំនុំជំរះក្តីខាងសង្គ្រាម ឬ ខាងចម្បាំង ។

អធិ. សាលយុទ្ធតុលាការនេះ < សាល «សាលា» + យុទ្ធ «ចម្បាំង, សង្គ្រាម, សឹក» + តុលាការ «ការថ្លឹង, ការស្ទង់ មិនឲ្យមានល្អៀង, ក្រសួងជំនុំជំរះក្តី» បានដល់

សាលាតុលាការខាងអាជ្ញាសិក ឬ សាលាជំនុំជំរះក្តីខាងសង្គ្រាម ។

សាលាតុលាការ (Cour de justice) (អ.ថ. សា-ឡា-តុ-ឡា-) ន. (ម.) សាលាជំនុំជំរះក្តី, សាលាយុត្តិធម៌ ។

អធិ. សាលាតុលាការនេះ < សាលា « រោង » + តុលាការ « ការថ្លឹង, ការស្ទង់ មិនឲ្យមានល្អៀង, ក្រសួងជំនុំជំរះក្តី, បានដល់សាលាជំនុំជំរះក្តី ឬ មន្ទីរសម្រាប់វិនិច្ឆ័យកាត់ក្តីដោយយុត្តិធម៌ ។ ឧទា. សាលាតុលាការជាន់ខ្ពស់ (Haute Cour de justice) ។ល។

សាលាលោក (Labaye) (អ.ថ. សា-ឡា-) ន. (ម.; សំ. ឝាលាលោក) សាលាសម្រាប់លោក, មន្ទីរជំនុំជំរះក្តីក្នុងសាកលលោក ។

អធិ. សាលាលោកនេះ < សាលា « រោង » + លោក « សភាវៈដែលវិនាសទៅដោយក្តៅនឹងត្រជាក់ . . » បានដល់សាលាសម្រាប់ជំនុំក្នុងសាកលលោក ឬ មន្ទីរសម្រាប់ពិភាក្សា

វិនិច្ឆ័យការរបស់ពិភពលោក ។ ពាក្យនេះប្រើក្លាយថា សាលលោក ; សម័យបុរាណច្រើនហៅ សានលោក ឬ សាលាសានលោក ។

**សាលាសិក្សា** ( Ecole ) ( អ. ថ សា – លា – សិក – សា ) ន. ( សំ. ឝាលាសិក្សា ; ម. សាលាសិក្ខា ) សាលារៀន , សាលាសម្រាប់ហ្វឹកហាត់ចំណេះវិជ្ជា ។

អធិ. សាលាសិក្សានេះ < សាលា « រោង » + សិក្សា « រៀនសូត្រ , ហ្វឹកហាត់ ... » បានដល់សាលាសម្រាប់សិក្សាចំណេះវិជ្ជាផ្សេង ៗ ដូចជា: សាលាសិក្សាបែបថ្មី (Ecole Rénovée ) ។ សាលាសិក្សាមន្ត្រីសុខាភិបាល (Ecole des officiers de Santé ) ។ សាលាសិក្សាភូមិន្ទវិជ្ជាពេទ្យ ( Ecole Royale de Médecine ) ។ សាលាសិក្សានាយទាហាន ( Ecole des officiers ) សាលាសិក្សាអនុវត្តន៍ ( Ecole d'Application ) ។ សាលាសិក្សាវិជ្ជាជីវៈ (Ecole profes-

sionelle) សាលាសិក្សាជាតិគរុវិជ្ជានារី (Ecole national d'institutrics) ។ សាលាសិក្សាពិសេសសាធារណការ (Ecole spéciale des Travaux publics) ។ សាលាសិក្សាជាតិវិជ្ជាជីវៈ (Ecole nationale professionelle) ។ សាលាសិក្សាជាងជើងស្បែកជើង (Ecole des maitres chaussures et bottiers) ។ សាលាសិក្សាគរុវិជ្ជាជាតិខាងការហាត់រៀន (Ecole normale nationale d'apprentissage) ។ សាលាសិក្សាជាតិបសុពេទ្យ (Ecole nationale vétérinaire) សាលាសិក្សាទន្តពេទ្យ (Ecole dentaire) ។ សាលាសិក្សាអគ្គិសនី និងគ្រឿងយន្តឧស្សាហកម្ម (Ecole d'électricité et de mécanique industrielle) ។ ល ។

សាវក ឬ សាវ័ក (Disciple) (អ. ថ. សា-វៈ-កៈ ឬ សា-វ័ក់) ន. (ប.សាវក; សំ. (ស្រាវក) អ្នកស្ដាប់, អ្នកស្ដាប់ឱវាទ, សិស្ស ។

អធិ. សាវក ឬ សាវ័ក នេះ បានដល់បុគ្គលអ្នកស្ដាប់ ខ្សាំង ឬ អ្នកកាន់ក្រឹត្យវិន័យរបស់គ្រូអាចារ្យ (ប្រើជាស្រាវក ឬ ស្រាវ័ក ក៏បាន; បើស្ដ្រីជា សាវិកា ឬ ស្រាវិកា) ឧទា. សាវ័កព្រះសម្ពុទ្ធ, សាវ័កនិគ្រន្ថ ។

សាស្ត្រាចារ្យ (Professeur n. m.) (អ. ថ. សាស-ស្ដ្រា–ចា) ន. (សំ. សាស្ត្រាចារ្យ; ម. សត្ថាចរិយ) អាចារ្យបង្រៀនសាស្ត្រ, គ្រូបង្រៀនវិជ្ជា ។

អធិ. សាស្ត្រាចារ្យនេះ < សាស្ត្រ «គម្ពីរ, ក្បួន, តម្រា, វិជ្ជា. . .» + អាចារ្យ «អ្នកប្រដៅ ឬ អ្នកហាត់មារយាទ, អ្នកប្រព្រឹត្តល្អ, អ្នកកាន់ត្រឹមត្រូវ, អ្នកត្រឹមត្រូវ, អ្នកដែលសិស្សត្រូវគោរព អ្នកធ្វើប្រយោជន៍ដល់សិស្ស, អ្នកបង្រៀនចំណេះគេ, គ្រូ, គ្រូបង្រៀន» បានដល់គ្រូបង្រៀនចំណេះវិជ្ជា ឬ គ្រូបង្ហាត់ក្បួន, តម្រា, គម្ពីរផ្សេងៗ ឧទា. សាស្ត្រាចារ្យជាប់កិច្ចសន្យា (Professeur contractuel)។

ស្ថាប័ន (Constructoin n.f. )ន. (សំ· ស្ថាបន, ម. ឋាបន) ការតាំងទុក ឬ ការដំកល់ទុក ។

អធិ. ស្ថានប័ន នេះ សំដៅយកការតាំងទុកឬដំកល់នូវវត្ថុមួយមិនឲ្យសាបសូន្យ ។

ស្ថានទ័ព( Base militaire )ន. (សំ. ស្ថានទ្រ័; ម. ឋានទ័) ក្បួនរេហ៍ពល, កន្លែងកងទ័ព ។

អធិ. ស្ថានទ័ពនេះ < ស្ថាន «ទីកន្លែង» + ទ័ព«រេហ៍ពល, ទាហាន, កងសេនា» បានដល់កន្លែងសម្រាប់សេនាទាហាន តែរឿងច្រើនប្រើសំដៅសេចក្ដីថាក្រុមរេហ៍ពល,ផ្នែកកងទាហាន ។

ស្ថានភាព ( Position n.f. ou Situation n.f. ) (ក. ថ ស្ថា- ន៑: -) ន. (សំ ·ស្ថានភាវ; ម· ឋានភាវ) ភាពនៃទី, ភាពជាទីតាំង, ភាពនៃដំណើរជាទីតាំង ។

អធិ· ស្ថានភាពនេះ ប្រើតាមស័ព្ទបារាំងថា «Position» ឧទា. ស្ថានភាពឋិតិវន្ត (Position statique) ប្រើតាមស័ព្ទបារាំង

ថា «Situation» នេះ ប្រែថា ស្ថានការណ៍ក៏បាន, ដែលប្រែថា ស្ថានភាព ។ល។ ស្ថានភាពលទ្ធពន្ធ (Situation de recouvrement) ។ល។

ស្ថានអធិការបតី (Chancellerie n.f.) (អ.ថ. ស្ថាន-ធិ-កា-រៈ-ប៉ៈ-) ទីឬកន្លែងរបស់អធិការបតី គឺជនជាម្ចាស់អ្នកត្រួតត្រា ។

អធិ· ស្ថានអធិការបតីនេះ < ស្ថាន «ទី, កន្លែង, ទីតាំង ទីដំកល់.· .» អធិការ អ្នកត្រួតត្រា, អ្នកគ្រប់គ្រង» +បតី «ម្ចាស់, នាយ ចៅហ្វាយ» បានដល់ស្ថានរបស់អធិការបតី គឺទីឬកន្លែងរបស់នាយកជាអ្នកត្រួតត្រា ។

ស្ថានឯកអគ្គរាជទូត (Ambassade)(អ. ថ. ស្ថាន-ឯក-អាក់-ក-រ៉ៈ-ទូត). ន. (សំ.) កន្លែងរបស់អ្នកបម្រើប្រសើរឯករបស់ព្រះរាជា ឬ កន្លែងជាទីតាំងសម្រាប់រាជទូតប្រសើរឯក ។

អធិ. ស្ថានឯកអគ្គរាជទូតនេះ < ស្ថាន « ទី, កន្លែង, ទីតាំង, ទីដំកល់ ... » + ឯក « មួយ, ទីមួយ, ... » + អគ្គ « ប្រសើរ, វិសេស, ដើម, ថ្លៃថ្លា... » + រាជ « ស្តេច » + ទូត « អ្នកដែលគេបញ្ជូន, ដែលគេប្រើទៅ ; អ្នកនាំការ, នាំដំណឹងពីម្ខាងទៅម្ខាង », បានដល់ស្ថានរបស់រាជទូតយ៉ាងវិសេសមួយ ឬ ការិយាល័យរបស់អ្នកនាំការពីម្ខាងទៅម្ខាងយ៉ាងប្រសើរឯករបស់ព្រះរាជា ។

## ស្ថានីយអាកាសយានជាតិ (Aérogare nationale)

(អ. ប. ស្ថា-នី-អា-កា-សៈ-យា-នៈ-ជាត) ន. (សំ.) ចំណតអាកាសយានជាតិ ; កន្លែងសំចតយន្តហោះជាតិ ។

អធិ. ស្ថានីយអាកាសយានជាតិនេះ < ស្ថានីយ « ទីសម្រាប់សំណាក់, ទីសំចត, ទីចត, ដំណាក់សម្រាប់ឈប់សម្រាក ... » + អាកាសយាន « យានដែលសញ្ចរទៅតាមវាលល្ហល្ហោរ, ដំនិះដែលត្រាច់ទៅតាមផ្លូវអាកាស, យន្តហោះ + »

ជាតិ «កំណើត» បានដល់ទីសម្រាប់សំណាក់យន្តហោះ ជាតិ ឬ បំណតសម្រាប់អាកាសយានជាតិ ។

ស្ថានីយអយស្ម័យយាន (Gare des chemins de fer) (អ. ប. ស្ថា – នី – អ: – យស់ – ស្ម – យាន) ន. (សំ. ម. កូ.) ចំណតរថភ្លើង, កន្លែងសំបតរទេះភ្លើង, ដំណាក់រទេះភ្លើង។

អធិ. ស្ថានីយអយស្ម័យយាននេះ < ស្ថានីយ "ទីសម្រាប់សំណាក់, ទីសំបត, ទីបត, ដំណាក់សម្រាប់ឈប់សម្រាក..." + អយស្ម "ដែលធ្វើដោយដែក, ដែលយកដែកធ្វើ, ដែលជាដែក" + យាន "គ្រឿងដឹកនាំ, គ្រឿងនាំបន្ទុកទៅមក, គ្រឿងសម្រាប់ជិះ, ជំនិះ" បានដល់ដំណាក់រទេះភ្លើង ឬ បំណតសម្រាប់រថភ្លើងឈប់សម្រាក ។

ស្ថាបត្យកម្ម (Architecture n. f.) (អ. ប. ស្ថា – ប័ត-ត្យ: – កម) ន. (សំ. ម. កូ.) អំពើដែលធ្វើឲ្យតាំងនៅ,

ការងារដែលគេដំកល់ទុក ។

អធិ. ស្ថាបត្យកម្មនេះ < ស្ថាបត្យ "ដែលគួរដំកល់ទុក, គួរតាំងទុក, ដែលត្រូវដាក់ទុក ..." + កម្ម "អំពើ, កិច្ចការដែលត្រូវធ្វើ, ការងារ" បានដល់អំពើដែលគេត្រូវដំកល់ទុក ឬ កិច្ចការដែលគេដំកល់ទុក ។

**ស្ថាបត្យករ** (Architecte) (អ. ថ. ស្ថា–ប៉ុត–ត្យៈ–ក) ន. (សំ. ម. ក.) អ្នកដំកល់ការងារទុក ឬ អ្នកធ្វើកិច្ចការដែលគេដំកល់ទុក ។

អធិ. ស្ថាបត្យករនេះ < ស្ថាបត្យ "ដែលគួរដំកល់ទុក, គួរតាំងទុក, ដែលត្រូវទុកដាក់..." + ករ "អ្នកធ្វើ" បានដល់អ្នកទុកដាក់នូវអំពើដែលគេត្រូវធ្វើ ។

**ស្ថាបនា ឬ ស្ថាប័ន** (Construction ou Institution) (អ.ថ. ស្ថា–ប៉ះ–នា ឬ–ប័ន) ន.(សំ) សំណង់. ការតាំងទុក, ការតាក់តែង ឬ តែងតាំង, ការសង់, ការសាងសង់ ។

អធិ. ស្ថាបនា ឬ ស្ថាប័ន នេះ បានដល់ការតាក់តែង ឬសង់របស់អ្វីឲ្យកើតឡើងជាគ្រោងរូបរាងសណ្ឋានទ្រង់ទ្រាយ ។

ស្ថាបនិក (Constructeur) (អ. ថ. ស្ថា–ប៉ៈ–និកៈ) (សំ; ម. ឋាបនិក) អ្នកតាំងទុក, អ្នកដំកល់ទុក, អ្នកតាក់តែង ឬ តែងតាំង, អ្នកសង់, អ្នកសាង ។

អធិ. ស្ថាបនិកនេះ សំដៅយកបុគ្គលអ្នករៀបចំតាក់តែងធ្វើរបស់អ្វីផ្សេងៗ ឬអ្នកសង់វត្ថុអ្វីឲ្យកើតឡើង មានសង់ទីលំនៅ ជាដើម ។

សិក្ខាបទ (Précepte n.m.) (អ. ថ. សិក – ខាបត់) ន. (ម.) ចំណែក, មាត្រារបស់សីល ឬ របស់វិន័យ ។

អធិ. សិក្ខាបទនេះ < សិក្ខា « សិក្សា, ការរៀនសូត្រ, ការហ្វឹកហាត់ ... » + បទ « ចំណែក, មាត្រា, ហេតុ, ដំណើរទំនង ... » បានដល់ចំណែក ឬ មាត្រាច្បាប់នៃការ

សិក្សាហាត់រក្សាមារយាទឲ្យមានរបៀបបែបផែន ។

សិក្ខាសាលា ( Séminaire n.m. ) (អ. ថ. សិក– ខា – សា – លា៉ ) ន. ( ម. ) កន្លែងសម្រាប់សិក្សា , ផ្ទះសម្រាប់រៀនសូត្រ ។

អធិ. សិក្ខាសាលានេះ < សិក្ខា « សិក្សា , ការរៀនសូត្រ , ការហ្វឹកហាត់ . . . » + សាលា « កន្លែង , ផ្ទះ មន្ទីរ » បានដល់សាលាសម្រាប់សិក្សា ឬ កន្លែងសម្រាប់រៀនសូត្រចំណេះវិជ្ជាផ្សេង ៗ ។

សិក្សា ( Instruction n.f. ) ( អ. ថ. សិក– សា ) ន. ( សំ. ; ម. សិក្ខា ) ការរៀន , ការសូត្ររៀន , ការហ្វឹកហាត់ , ការប្រឹងប្រយ័ត្នរក្សាមារយាទឲ្យល្អ , វិជ្ជា ។

អធិ. សិក្សានេះ បានដល់ការរៀនសូត្រ ទន្ទេញ ហ្វឹកហាត់ចំណេះផ្សេង ៗ ឲ្យបានចេះដឹង មានការសិក្សាវិជ្ជាអក្សរសាស្ត្រនិងប្រវត្តិសាស្ត្រជាដើម ។

សិក្សាធិការ (Censeur) (អ. ថ. ស៊ិក-សា-ធិ-ការ) ន. (សំ.; ម. សិក្ខាធិការ) អ្នកត្រួតត្រាការសិក្សា, អ្នករក្សា ឬ គ្រប់គ្រងខាងការរៀនសូត្រ ។

អធិ. សិក្សាធិការនេះ < សិក្សា «ការរៀន, ការសូត្ររៀន, ការហ្វឹកហាត់ ...» + អធិការ «អ្នករក្សា, អ្នកគ្រប់គ្រង, អ្នកត្រួតត្រា» បានដល់អ្នករក្សាខាងការសិក្សា ឬ អ្នកគ្រប់គ្រងការរៀន ឧទា. សិក្សាធិការវិទ្យាល័យ (Censeur du Lycée) ។

ស្ថិតិវន្ត (Position statique) (អ. ថ. ស្ថិ-តិ-វ័ន) ន. (សំ.; ម. ឋិតិវន្ត) ការតាំងនៅ, ការដំកល់, អ្នកឋិតនៅ ។

អធិ. ស្ថិតិវន្តនេះ បានដល់ការតាំងនៅ ឬ មនុស្សដែលមានការតាំងនៅ ។

សិទ្ធិបុព្វក្រយ (Droit de préemption.) (អ. ថ. ស៊ិត-ធិ-បុប-ពៈ-ក្រៃ) ន. (សំ. សិទ្ធិបូវក្រយ; ម. សិទ្ធិបុព្វកយ) អំណាចទិញជាខាងដើម, ច្បាប់ទិញដើមដំបូង ។

អធិ· សិទ្ធិបុព្វក្រ័យនេះ < សិទ្ធិ "សេចក្ដីសម្រេច, សេចក្ដីសម្រេចផល ឬ ផលសម្រេច, ការសម្រេចប្រយោជន៍, អំណាច, សេចក្ដីអង់អាច, សេចក្ដីសម្រេចតាមអំណាចច្បាប់ ..." + បុព្វ "មុន, មុនដំបូង, ដើម, ខាងដើម ..." + ក្រ័យ "ទិញ" បានដល់ច្បាប់ទិញដំបូង ឬ សិទ្ធិទិញមុនដំបូង ។

**សិទ្ធិលាភី** (Ayants-droit) (អ. ថ. សិត – ធិ –) ន. (ម.) អ្នកបាននូវអំណាច, អ្នកបានសិទ្ធិ ។

អធិ សិទ្ធិលាភីនេះ < សិទ្ធិ "សេចក្ដីសម្រេច, សេចក្ដីសម្រេចផល ឬ ផលសម្រេច; ការសម្រេចប្រយោជន៍, អំណាច, សេចក្ដីអង់អាច, សេចក្ដីសម្រេចតាមអំណាចច្បាប់..." + លាភី "អ្នកបាន ..." បានដល់អ្នកដែលមានសិទ្ធិលើវត្ថុណាមួយ ឬ អ្នកដែលបានអំណាចលើរបស់អ្វីមួយ ។

**សិទ្ធិសមាជិក** (Membre de droit) (អ. ថ. សិត – ធិ - សៈ - មា –) ន. (ម.) សមាជិកខាងច្បាប់, ក្រុមជំនុំ

ខាងសម្រេចច្បាប់ ។

អធិៈ សន្និសមាជិកនេះ < សន្និ « សេចក្ដីសម្រេច, ច្បាប់, ច្បាប់បញ្ញត្តិ, អំណាច, សេចក្ដីអង់អាច...» + សមាជិក អ្នកមានអំណាចត្រូវចូលកាន់ទីប្រជុំឋាន, អ្នកចូលក្នុងសមាគម» បានដល់សមាជិកខាងជំនុំធ្វើច្បាប់ឬតែងតាំងច្បាប់, សម្រេចច្បាប់ ។

**សន្និទ្ធភាព** (Cordialité n.f.) (អ·ជ· សន់-និត-ធៈ-ភាប) ន. (ប.- ភាវ, សំ- ស្និទ្ធភាវ) ភាពជិតស្និទ្ធ, ភាពល្អិតល្អ ។

អធិ, សន្និទ្ធភាពនេះ < សន្និទ្ធ «ជិតស្និទ្ធ, ល្អិតល្អ...» + «ភាព បែបបទ, លំនាំ, ឫកពា..» បានដល់ភាពនៃអាការជិតស្និទ្ធ, ភាពល្អិតល្អ ។

អធិ. សន្និទ្ធភាពនេះ < សន្និទ្ធ, «ជិតស្និទ្ធ, ល្អិតល្អ, + ភាព «ភាវៈ, បែបបទ, លំនាំ, ឫកពា...» បានដល់ ភាពនៃអាការជិតស្និទ្ធ ឬ ភាពដ៏ល្អិតល្អ ដែលជាទីស្រឡាញ់

ជាទីពេញចិត្ត ។

សិប្បីវប្បកម្ម (Ostréiculture n.f.) (អ.ថ. សិប-ប៉ិ-វ៉័ប-ប៉ៈ-ក័ម) ន. (ម.) ការចិញ្ចឹមគ្រំ ។

អធិ. សិប្បីវប្បកម្មនេះ < សិប្បី «គ្រំ, ខ្យង, លៀស, ខ្ចៅ...» + វប្បកម្ម «ការចិញ្ចឹម, ការបណ្ដុះបណ្ដាល, ការកាស់...» បានដល់ការចិញ្ចឹមសិប្បីជាតិមានខ្យង, គ្រំ, លៀស, ខ្ចៅ, ងាវ ជាដើម ។

សិប្បីវប្បករ (Ostréiculteur n.m.) (អ.ថ. សិប-ប៉ិ-វ៉័ប-ប៉ៈ-ក) ន. (ម.) អ្នកចិញ្ចឹមគ្រំ ។

អធិ. សិប្បីវប្បករនេះ < សិប្បី «គ្រំ, ខ្យង, លៀស, ខ្ចៅ...» + វប្បករ «អ្នកចិញ្ចឹម, អ្នកបណ្ដុះបណ្ដាល, អ្នកកាស់...» បានដល់អ្នកចិញ្ចឹមសិប្បីជាតិ មានខ្យង, គ្រំ, លៀស, ខ្ចៅ, ងាវ ជាដើម ។

សិលាលេខកៈ (Lithographe n.m.) អ.ថ. សិ–លា–លេ–ខៈ–កៈ ) ន. (ម) អ្នកអក្សរថ្ម, អ្នកចេះអក្សរថ្ម ។

អធិ. សិលាលេខកៈនេះ < សិលា «ថ្ម» + លេខកៈ «អ្នកលិខិត, អ្នកសរសេរ, អ្នកចារឹក...» បានដល់អ្នកចេះមើលចេះសរសេរផ្នែកខាងអក្សរសិលាចារឹក គឺអក្សរថ្ម ឬហៅថា អ្នកសិលាលេខ ។

សិល្ប (Arttste) (អ.ថ សិល ) ន. (សំ. ឝិល្ប; ម. សិប្ប) សិប្បៈ; ចំណេះ ។

អធិ. សិល្បនេះ បានដល់ចំណេះវិជ្ជាខាងពួកជាងរចនាក្បូរក្បាច់ ចម្លាក់ ។ល។

សិល្បករ (Artiste) (អ.ថ. សិល–ប៉ៈ–ក ) ន. (សំ. ឝិល្បករ; ម. សិប្បករ ) ជាងរចនា, អ្នកជំនាញ ។

អធិ. សិល្បករនេះ បានដល់ពួកជាងរចនា ដែលស្ទាត់

ជំនាញខាងធ្វើការគូរ – ឆ្លាក់ – ក្បូរក្បាច់ – រំលប របនាគ្រប់បែបគ្រប់យ៉ាង ។

សិល្បវត្ថុ (Objet d'art ) ( អ. ថ. សិល – ប៉ះ – វ័ត – ថុ ) ន. ( សំ. ឝិល្បវស្តុ ; ប. សិប្បវត្ថុ ) ប្រដាប់ប្រដានៃពួកជំនាង, ភណ្ឌៈរបស់ជាង ។

អធិ. សិល្បវត្ថុនេះ < សិល្ប « សិប្បៈ, ជំនាង, ការជាងផ្សេងៗ, ហត្ថកម្មគ្រប់យ៉ាង . . . » + វត្ថុ « របស់ជាទីតាំង, ភណ្ឌៈ, អីវ៉ាន់, គ្រឿងប្រដាប់, ប្រដាប់ប្រដា . . . » បានដល់វត្ថុនៃសិប្បៈ គឺប្រដាប់ប្រដាខាងជំនាងផ្សេងៗ ឬ ដើមហេតុនៃចំណេះដែលត្រូវសិក្សាដោយដៃជាដើម ។

សិស្សសាលាសិក្សាពហុបច្ចេកទេស ( Polytechnicien n.m. ) ( អ. ថ. សិស – សា – ល៉ា – សិក – សា – ពៈ – ហ៊ុ – ប័ច – ចេ – កៈ – ) កូនសិស្ស

សាលារៀនសូត្រដោយចំណែកច្រើន , សេចក្ដីផ្សេងដោយចំណែកច្រើនខាងការរៀនសូត្ររបស់សិស្សសាលា ។

អធិ. សិស្សសាលាសិក្សាពហុបច្ចេកទេសនេះ < សិស្ស « អ្នកស្ដាប់ឱវាទ , អ្នកធ្វើតាមបង្គាប់គ្រូ . . . » + សាលា « រោង , ផ្ទះ , មន្ទីរ » + សិក្សា « រៀនសូត្រ , រៀនទន្ទេញ , ហ្វឹកហាត់ ; . . » + ពហុ « ច្រើន » + បច្ចេកទេស « ចំណែកផ្សេង , ដោយចំណែកមួយ » បានដល់កូនសិស្សដែលរៀនសូត្រ នូវសាលារៀនមានចំណែកផ្សេងដោយច្រើន ។

សិសិរៈ ( Hiver n.m. ) ( អ. ថ. សិ – សិ – រ: ) ន. ( ម. សិសិរ ; សំ. ឝិឝិរ ) រដូវរងាខ្លាំង , រដូវត្រជាក់ខ្លាំង ។

អធិ. សិសិរៈនេះ បានដល់ឈ្មោះរដូវទី ៤ ក្នុងបែបចែករដូវ ៤ ឬ ឈ្មោះរដូវទី ២ ក្នុងបែបចែករដូវ ៦ ។ ពាក្យនេះ

ប្រើជា គុ. សំដៅសេចក្ដីថា « ត្រជាក់ខ្លាំង , រងា , រងាខ្លាំង »

ឧទា. ឧតុសិសិរៈ រដូវត្រជាក់ខ្លាំង ឬ រងាខ្លាំង ។

សីតុណ្ហភាព ( Température n.f. ) ( អ. ថ. សីតុន – ណ្ហ: – ភាប ) ន. ( ម. – ភាវៈ ) ភាពនៃត្រជាក់និងក្ដៅ , ភាពនៃរដូវត្រជាក់និងក្ដៅ ។

អធិ. សីតុណ្ហភាពនេះ < សីត « ត្រជាក់ » + ឧណ្ហ « ក្ដៅ » + ភាព « ភាវៈ , បែបបទ , លំនាំ , ឫកពា... » បានដល់ ភាពនៃត្រជាក់និងក្ដៅ ឬ ភាពនៃរយៈកាលត្រជាក់និងក្ដៅ ។

សីលធម៌ ( Moralité n.f. ) ( អ. ថ. សី – ល: – ធ័រ ) ន. ( សំ. ឝីលធម៌ ; ម. សីលធម្ម ) សីលដែលជាធម៌ ( របស់សត្វលោក ) ; ច្បាប់សណ្ដាប់ធ្នាប់របស់មនុស្ស ។

អធិ. សីលធម៌នេះ < សីល « ការកាន់ចរិយាល្អ , ការសង្រួម , អត្តចរិយា , ចរិត , ចរិយា , មារយាទល្អ , សេចក្ដីល្អ , គតិ , លក្ខណៈ , និស្ស័យ , អធ្យាស្រ័យ ,

សភាព , ប្រក្រតី , ទម្លាប់ , សណ្ដាប់ធ្នាប់ , ធម្មជាតិ ; ធម្មតា » + ធម៌ « ច្បាប់ , សភាវៈដែលទ្រទ្រង់សត្វលោក » បានដល់ច្បាប់ចរិយាសណ្ដាប់ធ្នាប់ដែលមនុស្សប្រព្រឹត្ត ។

**សុក្រឹត** (Parfait adj.) គុ. (សំ. សុក្ឫត ; ម. សុកិត) ដែលធ្វើឲ្យល្អ , ដែលធ្វើឲ្យត្រឹមត្រូវ , ដែលធ្វើឲ្យស្រួល ។

អធិ. សុក្រឹតនេះ បានដល់ស័ព្ទសម្រាប់ប្រើជា គុ. របស់នាមស័ព្ទ ដែលថា ធ្វើឲ្យល្អ ឲ្យត្រឹមត្រូវ ។ល។

**សុក្រឹតភាព** (Parfaitement adv) (អ.ថ. សុ-ក្រឹ-តៈ-ភាប ) កិ.វិ. ឬ ន. (សំ. សុក្ឫតភាវ ; ម. សុកិតភាវ) ភាពនៃរបស់ដែលគេធ្វើឲ្យគ្រប់លក្ខណៈ , ភាពនៃវត្ថុដែលគេធ្វើឲ្យល្អ ។

អធិ. សុក្រឹតភាពនេះ មកពីស័ព្ទថា សុក្រឹត « ដែលគេធ្វើឲ្យល្អ , ដែលគេធ្វើឲ្យគ្រប់លក្ខណៈ... » + ភាព «ភាវៈ , បែបបទ , លំនាំ , ឫកពា . . . » បានដល់ភាពនៃរបស់ដែល

គេធ្វើឲ្យគ្រប់លក្ខណៈ ឬ ភាពនៃវត្ថុដែលគេធ្វើឲ្យល្អ ។

សុខដុម ( Harmonie n.f. ) ( អ. ថ. សុ – ខៈ – ដុំ ) ន. ( ម. សុខតម ) សុខក្រៃលែង , សប្បាយលើសលុប , ស្រួលក្រៃពេក ។

អធិ. សុខដុមនេះ បានដល់ការនៅផ្ដុំគ្នា ឬនៅជាសុខតមោះហ្មង ឬក៏សេចក្ដីសប្បាយដោយការនៅមូលគ្នា ជា សុខស្រួល ( ព. បុ. ) ឧទា. រកស៊ីដោយសុខដុម , នៅរួមគ្នាដោយសុខដុម ។

សុខុមាលភាព ( Bien-être n.m. ) ( អ. ថ. – មា – លៈ – ភាប ) ន. ( ម. – ភាវ ) ភាពដ៏ល្អិតល្អន់ , ភាពដែលបរិបូណ៌ដោយសេចក្ដីសុខ ។

អធិ. សុខុមាលភាពនេះ < សុខុមាល « ដ៏ល្អិតល្អន់ , ល្អិតទន់ , ដ៏ផូរផង់ ... » + ភាព « ភាវៈ , បែបបទ , លំនាំ , បុគពា ... » បានដល់ភាពដែលបរិបូណ៌ដោយសេចក្ដី

ក្តីសុខ ឬ ភាពនៃបុគ្គលដែលធ្លាប់បរិបូណ៌ដោយសេចក្តីសុខដ៏ល្អិតល្អន់ ។

សុង្កការ ( Percepteur n.m. ) ( អ. ថ. សុង្ក – ការៈ – រ៉ ឬ សុង្ក – ការ៉ ) ន. ( ម. ) អ្នកហូតពន្ធ , អ្នកធ្វើការខាងយកពន្ធ , អ្នកធ្វើការខាងដកហូតកាសុី ។

អធិ. សុង្កការនេះ < សុង្ក «ស្ពួយ , អាករ , ពន្ធ , កាសុី» + ការ «អ្នកធ្វើការ ; ជនអ្នកធ្វើ» បានដល់អ្នកធ្វើគយ ឬ អ្នកយកកាសុី គឺជនអ្នកហូតពន្ធ ឬ អ្នកទារថ្លៃកាសុី ។

សុង្កដ្ឋាន ( Perceptio n.f. ) ( អ.ថ. សុង្ក– កដ– ឋាន ) ន. ( ម. ) កន្លែងបង់ពន្ធ , ទីគយ , កន្លែងដែលមានយកកាសុី , មុខកាសុី ។

អធិ. សុង្កដ្ឋាននេះ < សុង្ក «ស្ពួយ , អាករ , ពន្ធ , កាសុី» + ឋាន «ទី , កន្លែង , ទីតាំង , ទីដំកល់ ...» បានដល់កន្លែងសម្រាប់ហូតពន្ធ ឬ ទីសម្រាប់ធ្វើការរបស់អ្នក

យកពន្ធយកការស៊ី ។

សុង្កទាយក (Tributaire n.m.) (អ.ថ. សុង-កៈ-ទា-យក់) អ្នកបង់ពន្ធ, អ្នកប្រគល់ប្រាក់ពន្ធ, អ្នកបង់តម្លៃការស៊ី ។

អធិ. សុង្កទាយកនេះ < សុង្ក «សួយ, អាករ, ពន្ធ, ការស៊ី» + ទាយក «អ្នកឲ្យ, អ្នកប្រគល់, អ្នកបង់» បានដល់អ្នកប្រគល់ប្រាក់ពន្ធ ឬ ប្រាក់ការស៊ី, អ្នកបង់ពន្ធ ឬ បង់ការស៊ី ។

សុង្កាករ ( Tribut n.m. ) ( អ. ថ. សុង-កា-ក ) ន. ( ម. ; សំ. ឝុល្កាករ ) ប្រាក់ពន្ធ, ប្រាក់ថ្លៃការស៊ី ។

អធិ. សុង្កាករនេះ < សុង្ក « សួយ, ពន្ធ, ផាស៊ី » + អាករ « កំណប់ទ្រព្យ, គំនរ, ពូក, ក្រុម, ដង្ហាយ ; ជំនូន . . . » បានដល់ប្រាក់ពន្ធ ឬ ប្រាក់ដែលដកហូតការស៊ីអំពីជនអ្នកលក់ដូរទំនិញចេញចូលសព្វសារពើ ។

សុជីវធម៌ ឬ សុជីវភាព ( Savoir-vivre n.m. )

( អ. ថ. សុ – ជី – វៈ – ) ន. ( ម. – ធម្ម ឬ – ភាវៈ ) សភាពជាគ្រឿងចិញ្ចឹមជីវិតងាយ ឬ ភាពនៃការចិញ្ចឹមជីវិតស្រួល ។

អធិ. សុជីវធម៌ ឬ សុជីវភាពនេះ < សុ « ប្រពៃ, ងាយ, ស្រួល, ល្អ ... » + ជីវ « ការរស់នៅ, ការចិញ្ចឹមជីវិត .. » + ធម៌ ឬ ភាព « សភាព ឬ ភាវៈ, បែបបទ » ។ បានដល់សភាពនៃការរស់នៅដោយងាយ ឬ ភាពនៃការចិញ្ចឹមជីវិតស្រួល ។

សុញ្ញាកាស ( Vide n.m. )( អ. ថ. សុញ – ញ៉ា – ) ន. ( ម. ) អាកាសសូន្យ, អាកាសស្ងាត់ឈឹង, ប្រទេសវាលទទេ, ទីវាលធេងទទេសូន្យ ។

អធិ. សុញ្ញាកាសនេះ < សុញ្ញា « សូន្យ, សោះសូន្យ, ទទេ, ទំនេរ, ស្ងាត់, ឥតប្រយោជន៍, ដែលបាត់សោះ » + អាកាស « ប្រទេសវាលល្ហល្ហាធ្លុងធ្លោ, ទីវាលធេងទទេ, ចន្លោះធេងទទេ;

លំហមេឃ, ទីអាកាសដែលមានផ្លូវខ្យល់, ចន្លោះដែលមានខ្យល់ចេញចូលបាន» សំដៅយកអាកាសដែលសូន្យទទេ ឬ ប្រទេសវាលស្រឡះល្ហល្ហេវផុតគ្រឿងស្ទាក់ឈើ ។

ស៊ុន្ទរកថា (Discours n.m.) (អ-ថ.ស៊ុន-ទៈ-រៈ-កៈ-ថា) ន. (ម.) សំដីពីរោះ, សំដីគួរចង់ស្ដាប់, សំដីគួររីករាយ, សំដីនិយាយពីរោះគួរចាប់ចិត្ត ។

អធិ. ស៊ុន្ទរកថា នេះ < ស៊ុន្ទរ «ល្អ, ពីរោះ, ផ្អែម.....» + កថា «ពាក្យ; សំដី; វាចាជាហេតុពោល, និយាយ, ថ្លែង» បានដល់សំដី ឬ វាចាជាហេតុពោលគួរឲ្យចង់ឮ ចង់ស្ដាប់ ជាសំដីពីរោះគួរចាប់ចិត្ត ។

ស៊ុភមង្គល (Bonheur n.m.) (អ.ថ. ស៊ុ-ភៈ-ម័ង-គល់) ន. (សំ.ម.) មង្គលល្អ, សេចក្ដីចម្រើនដ៏ល្អ, គ្រោះល្អ, ជោគល្អ ។

អធិ. ស៊ុភមង្គលនេះ < ស៊ុភ «ល្អ, ថ្លៃថ្នូ, សោភ័ណ

ថ្ងៃថ្លា, សោភណ៍ ...» + មង្គល «សេចក្តីចម្រើន, សេចក្តីសុខ, ហេតុដែលនាំឲ្យកើតសេចក្តីសុខ - ចម្រើន, ស្រីសួស្តី» បានដល់សេចក្តីចម្រើន សិរី សួស្តី ជោគជ័យដ៏ល្អ ។

សុភាសិត (Maxime n.f.) ន. (ម. ; សំ. សុភាសិត) ពាក្យពីរោះ, ពាក្យល្អ, ឱវាទត្រឹមត្រូវ, ពាក្យទូន្មានល្អ ។

អធិ. សុភាសិតនេះ បានដល់ពាក្យដែលអ្នកប្រាជ្ញសំដែងដោយល្អ ឬពាក្យឱវាទពីរោះដែលមានប្រយោជន៍គួររៀនគួរស្តាប់ ។

ឧទា. ធ្វើបុណ្យនឹងបាប អំពើសុភាព នោះរាល់តែនឹងតាម ប្រដូចស្រមោល អន្ទោលតាមប្រាណ ពុំដែលចៀសបាន ត្រង់ក្តីទុក្ខសោក ។

សុលកាការ (Douane n.f.) (អ. ថ. សុ-ល: កា-ក) ន. (សំ. ឝុល្កាគារ; ម. សុង្កាគារ) ប្រាក់ពន្ធ, ប្រាក់ភាសី ។

អធិ. សុលកាការនេះ < សុលក «សួយ, ពន្ធ, ភាសី, + អាគារ «កំណាប់ទ្រព្យ, គំនរ, ពូក, ក្រុម, ជង្ហុយ, ជំនួន...»

បានដល់អាករដែលបានមកអំពីការយកការស៊ី ឬ អាករខាងគយ ដែលពិនិត្យត្រួតត្រាហូតពន្ធទំនិញចេញចូល ។

**សេដ្ឋកិច្ច** (Economie n.f.)(អ. ថ. សេត–ថៈ កិច)ន. (ម.) កិច្ចដ៏ប្រសើ, អំពើដែលគេធ្វើយ៉ាងថ្លៃថ្លា ។

អធិ. សេដ្ឋកិច្ចនេះ < សេដ្ឋ « ប្រសើរ, វិសេស, ថ្លៃថ្លា » + កិច្ច « អំពើ, ការងារដែលគេត្រូវធ្វើ » បានដល់ការងារខាងរបររកស៊ី ដែលគេត្រូវធ្វើឲ្យចម្រើនធនធាន និង ភោគសម្បត្តិដល់ប្រទេសជាតិមាតុភូមិ សំដៅយកផលរបរដែលជាផ្លូវជំនួញ ។ អ្នកសេដ្ឋកិច្ច ( Economiste n. ) ។ ក្រសួងសេដ្ឋកិច្ចជាតិ ( Ministère de l'Economie national) ។ ភូមិសាស្ត្រសេដ្ឋកិច្ច ( Géographie économique ) ។ ល ។

**សេនាធិការ** ( Etat-major n.m. ) ( អ. ថ. សេ–នា–ធិ–កា ) ន. ( សំ. ម. ) អ្នកបញ្ជាការកងទ័ព, អ្នកត្រួតត្រាកងទ័ព ។

អធិ. សេនាធិការនេះ < សេនា « ពួកទាហាន , ពួកពល , រេហ៍ពល , កងទ័ព » + អធិការ « អំណាច , សិទ្ធិ ឬ សិទ្ធិភាព , ការគ្រប់គ្រង , ការបង្គាប់បញ្ជា , បញ្ជាការ , មុខការ , មុខក្រសួង , ទីធ្វើរាជការ , ភារៈ , ច្បាប់ , ច្បាប់បញ្ញត្តិ , បំពូកសេចក្ដី , ដំណើរសេចក្ដី , អ្នកគ្រប់គ្រង , អ្នកត្រួតត្រា , អ្នកទទួលការខុសត្រូវ » បានដល់មេបញ្ជាការកងទ័ព ឬ អ្នកត្រួតត្រាពួកទាហាន ។ ពាក្យថា សេនាធិការនេះ បើតាមសព្ទបារាំងថា « Quartier Général » សំដៅយកទីបញ្ជាការកងទ័ព ឬ ទីស្ដីការខាងកងយោធា ។

សេនានី (Officier n.m.) (អ.ប. សេ–នា–នី) ន. (ម.) នាយទាហាន , នាយពល , មេទ័ព ។

អធិ. សេនានីនេះ បានដល់នាយទាហាន ឬ នាយពល អ្នកត្រួតត្រាទ័ព ។

សេនាទុតិក្ដ (Attaché militaire) (អ.ប. សេ–

នា-នុ–ព័ន្ធ) ន. (សំ.ម.–ពន្ធ) ការជាប់តាមកងទ័ព, ដំណើរជាប់ដំពាក់ដោយពួកទាហាន ។

អធិ. សេនានុព័ន្ធនេះ < សេនា «ពួកទាហាន, ពួកពល, រេហ៍ពល, កងទ័ព» + អនុព័ន្ធ «ការជាប់តាម, ដំណើរជាប់តាម» បានដល់ការជាប់តាមពួកកងទ័ព ឬ ដំណើរទាក់ទងដោយកងទ័ព ។

សេនាប្រមុខ (Maréchal n.m.) (អ.ថ. សេ–នា–ប្រ–មុខ) ន. (សំ. ; ម. សេនាបមុខ) ប្រមុខនៃកងទ័ព, អ្នកធំចម្បងលើកងទ័ព (ស្តេចសឹក) ។

អធិ. សេនាប្រមុខនេះ < សេនា «ពួកទាហាន, ពួកពល, រេហ៍ពល, កងទ័ព» + ប្រមុខ «អ្នកដែលជាប្រធាន, ជាធំ, ជាចម្បង, អ្នកដែលប្រសើរក្រៃលែង, ដែលជាឯក, ជាទីមួយ» បានដល់អ្នកនាំមុខ ឬអ្នកដែលជាទីចម្បងលើកងទ័ព គឺប្រមុខនៃពួកពល ឬ ស្តេចសឹក ។ ម.ព. អគ្គសេនានាយកផង ។

សេរី ( Libre adj. ) (អ. ថ. -រី) គុ. (ម.; សំ. ស្វៃរិន៍ ស្វៃរ+ឥន៍) ដែលមានអំណាចលើខ្លួន ។

អធិ. សេរីនេះ < សេរ ‹‹អំណាចលើខ្លួន›› + ឥន្ ‹‹មាន›› សម្រាប់ប្រើជា គុ. ថា: ‹‹ដែលមានអំណាចលើខ្លួន, ដែលអាចធ្វើអ្វីបានតាមអំពើចិត្តរបស់ខ្លួន ។

សេរីកា ( Libération n.f. ) ន. (ម.) ការអាចធ្វើអ្វីបានដោយអំណាចខ្លួន, ដំណើរដែលមានសេរី ។

អធិ. សេរីកានេះ បានដល់ការធ្វើអ្វីបានដោយអំណាចខ្លួន ឬដំណើរដែលអាចសម្រេចអ្វីៗ បានតាមចិត្ត ។

សេរីភាព (Liberté n.f.) (អ. ថ. សេ-រី-ភាប) ន. (ម. សេរីភាវ; សំ. ស្វៃរិភាវ) ភាពនៃបុគ្គលដែលមានអំណាចពេញទី, អំណាចដែលអាចធ្វើអ្វីបានតាមអំពើចិត្ត ។

អធិ. សេរីភាពនេះ < សេរី ‹‹ដែលអាចធ្វើអ្វីបានតាមចំនើនខ្លួនឯង, ដែលមានអំណាចលើខ្លួន›› + ភាព ‹‹ភាវៈ››,

បែបបទ, លំនាំ, ឬគតា ...» បានដល់ភាពដែលមានអំណាចលើខ្លួនឯង ឬ ជាឈ្មោះគណបក្សនយោបាយមួយ ហៅថា គណបក្សសេរីភាព ឬក៏ជាឈ្មោះសារពត៌មានមួយ ហៅថា សារពត៌មានសេរីភាព ។

សេរីរដ្ឋ (Etat libre) (អ.ថ. សេ-រ៉ី-រ័ត) ន.(ម.) រដ្ឋដែលមានអំណាចលើខ្លួនឯង, ដែនឬប្រទេសដែលមានអំណាចអាចធ្វើអ្វីបានតាមអំពើចិត្ត, ប្រជាជនដែលមានអំណាចពេញទី ។

អធិ. សេរីរដ្ឋនេះ < សេរី «ដែលមានអំណាចលើខ្លួនដែលអាចធ្វើអ្វីបានតាមចិត្ត» + រដ្ឋ «ដែន, ប្រទេស, អ្នកនៅក្នុងដែន, រាស្ត្រ, ប្រជាជន» បានដល់រដ្ឋដែលមានអំណាចលើខ្លួនឯង គឺមានអំណាចធ្វើអ្វីបានតាមទំនើងចិត្តខ្លួនឥតមានអ្នកណាត្រួតត្រា ជាប្រទេសមានរបបគ្រប់គ្រងដោយខ្លួនឯង មិនមែនជាប្រទេសនៅក្នុងអាណាព្យាបាលជនដទៃ ។

សោធន (Pension n.f.) (អ.ថ. សោ–ធៈ–នៈ ឬ–ធន៍) ន. (ម.) ការចំណាយ, ការជំរះ ឬ សំអាតទូទៅប្រយោជន៍ ។

អធិ. សោធននេះ បានដល់ការចំណាយ ឬ ជំរះទូទៅប្រាក់ សម្រាប់ប្រើការផ្សេងៗ ឲ្យត្រឹមត្រូវ ។ ឧទា. សោធនកាលិក (Pension temporaire) = ការចំណាយ ឬ ជំរះប្រាក់តាមកាលកំណត់; ការចំណាយត្រឹមត្រូវតាមកាលគួរ ។ សោធនកាលិកក្មេងកំព្រា (Pension temporaire d' orphelins) = ការចំណាយប្រាក់ ចំពោះក្មេងកំព្រាប្រកបដោយកាលកំណត់ ។

សោធនពិការភាព (Pension d' invalidité) ការចំណាយប្រាក់ សម្រាប់មនុស្សពិការ ។ សោធនមេម៉ាយប្ដីស្លាប់ (Pension de veuve)= ការចំណាយប្រាក់ចំពោះស្ត្រីប្ដីស្លាប់ ។ សោធនសមាមាត្រ (Pension proportionnelle) = ប្រាក់ចំណាយដែលគេរាប់ ឬ ស្ទង់ត្រឹមត្រូវ ។ សោធនអតីតភាព

( Pension d'ancienneté ) = ភាគនៃប្រាក់សោធនដែលប្រព្រឹត្តកន្លងទៅ ។ល។

សោមនស្ស (Satisfaction n. f.) (អ. ថ. – ម៉ៈ – ន័ស) (ម. ; សំ. សៅមនស្យ) សេចក្ដីពេញចិត្ត, សេចក្ដីរីករាយចិត្ត ។

អធិ. សោមនស្សនេះ សំដៅយកសេចក្ដីសប្បាយរីករាយចិត្ត ឬ សេចក្ដីពេញចិត្ត, អំណរ ឧទា. មានសោមនស្ស ។ ព. ផ្ទុ. ទោមនស្ស ។

សំយោគ (Synthèse n. f.) (អ. ថ. ស័ង - យោគ) ន. (សំ. ម.) ការប្រកប, ការផ្សំ, ការប្រមូល, ការទាក់ទងជាមួយ, ការនៅរួមគ្នា, ការពាក់ព័ន្ធ, សមាគមដ៏ជិតស្និទ្ធ ។

អធិ. សំយោគនេះ បើតាមពាក្យវិទ្យាសាស្ត្រថាៈ ការរួបរួមគ្នា ឧទាៈ ការរួមធាតុសុទ្ធ ( Corps simple ) បញ្ចូលគ្នាឲ្យក្លាយជាធាតុផ្សំ ( Corps composé ) ។ បើតាមពាក្យតក្ក–

សាស្ត្រ « Synthèse » ប្រែថា « សំយោគបទ » បានដល់សេចក្តីប្រមូលបុព្វហេតុផ្សេងៗ ដើម្បីឲ្យយល់ផល ។ បើតាមស័ព្ទបារាំងថា « Synthèse mathématique » ប្រែថា « សំយោគគណិតសាស្ត្រ » បានដល់ការប្រមូលរួមគ្នាខាងក្បួនលេខ ។ល។

**សំយោគិន** ( Synthésique adj. ) ( អ. ច. ស័ន – យោ – ) គុ. ( ម. ) ដែលមានការរួបរួម , ដែលមានលក្ខណៈជាគ្រឿងប្រកបផ្សំ ។

អធិ. សំយោគិននេះ បានដល់ស័ព្ទប្រើជា គុ. ថាៈ ដែលមានលក្ខណៈជាគ្រឿងប្រកប , ជាគ្រឿងរួបរួម ឧទា. វត្ថុនេះមានទិដ្ឋភាពជាសំយោគិន ។

**សំយោគី** ( Synthétique adj. ) ( អ. ច. ស័ន – ) គុ. ( ម. ) ដែលធ្វើដោយការប្រកបផ្សំ , ដែលធ្វើដោយប្រើវិធីរួបរួមគ្នា ។

អធិ. សំយោគីនេះ សំដៅយកការប្រើជា គុ. របស់នាមស័ព្ទថា ដែលធ្វើដោយប្រើវិធីសំយោគ គឺរបៀបប្រកបផ្សំ ឧទា.. កៅស៊ូសំយោគី (កៅស៊ូស្ង) ។

សំវិធានវត្ថុ (Provision n. f.) (អ. ថ. ស័ង-វិ-ធា-ន-វ័ត-ថុ) ន. (ម.) វត្ថុចាត់ចែងទុក, វត្ថុចាត់ចែងបម្រុង ។

អធិ. សំវិធានវត្ថុនេះ ‹សំវិធាន ‹‹ចាត់ចែងទុក, តាក់តែង, រៀបចំ,, + វត្ថុ ‹‹របស់ជាទីតាំង, កណ្ឌៈ, អំពិន, ទ្រព្យ, ទីលំនៅ, ចំការ, រឿង, ហេតុ, ដំណើរសេចក្ដី, ខ្លឹមសារ, គុណសម្បត្តិ,, បានដល់វត្ថុដែលគេចាត់ចែងរៀបចំទុកដាក់ ឬ វត្ថុដែលគេតាក់តែងបម្រុង ។ ល ។

‹‹ ឃ. គ. ប.,,

ន. ៣.

=<០>=

XXXXXX
X    X
X ហ X
XXXXXX

ហ= ព្យញ្ជនៈទី ៣១ តាមលំដាប់ពួកព្យញ្ជនៈ ៣៣ តួ, ជាព្យញ្ជនៈទី ៦ ក្នុងសេសវគ្គ ឬ អវគ្គ សម្រាប់ប្រើក្នុងភាសាសំស្រ្កឹត មគធៈ និងភាសាខ្មែរ, ជាកណ្ឋជៈ មានសំឡេងកើតក្នុងក- (gutturals), ជាអឃោសៈ មានសំឡេងមិនតឹកកង គឺសំឡេងតូច ឬ សំឡេងគ្រលួច (Sourdes), ហើយអាចបញ្ចេញសំឡេងបាន ២ យ៉ាង គឺនៅជា ហ ដដែលមួយយ៉ាង, ជា ហ៊ មួយយ៉ាង ដោយប្រើត្រីស័ព្ទឲ្យមានសំឡេងជាឃោសៈ វិញ ប៉ុន្តែប្រើបានចំពោះតែព្យាង្គគោលដូចពាក្យថា ហ៊ី, ហ៊ឺន ជាដើម ឬនៅ ខាងដើមព្យាង្គឯទៀតៗ កាលណាបើនៅខាងចុងព្យាង្គដែលមានអក្សរពីរតួឡើងទៅ មិនបាច់ដាក់ត្រីស័ព្ទឡើយ អាចបញ្ចេញសំឡេងទៅតាមអក្សរឃោសៈ ឬអឃោសៈដែលនៅខាងដើម ។

ហាយនភាព (Désastre) (អ. ប. ហា-យៈ-នៈ-

ភាប)ន.(សំ.ម.–ភាវ) ភាពនៃសេចក្ដីសាបសូន្យ, ភាវៈ ឬ ដំណើរនៃកិរិយាវិនាស ។

អធិ. ហាយនភាពនេះ < ហាយន «សេចក្ដីសាបសូន្យ, សេចក្ដីវិនាស, ដំណើរទ្រុឌទ្រោម» + ភាព «ភាវៈ, ធម៌, ធម្មជាត, បែបបទ, លំនាំ; បុគ្គល...» បានដល់ភាពនៃការសាបសូន្យ ឬ ភាវៈនៃសេចក្ដីវិនាសបាត់ស្ងាត់សោះសូន្យនៃសភាវធម៌ទាំងពួង ។

ហិតប្រយោជន៍ (Rendre service) (អ. ថ. ហិ–តៈ–ប្រ–យោ៉ច) ន. (សំ.–ប្រយោជន, ម. ហិតបយោជន) ប្រយោជន៍ដ៏សំខាន់, ប្រយោជន៍ដ៏ចម្រើន, ផលប្រយោជន៍ដ៏ល្អ ។

អធិ. ហិតប្រយោជន៍នេះ < ហិត «ប្រយោជន៍; សេចក្ដីចម្រើន, ថ្លៃថ្លា, ដ៏សំខាន់, វិសេស...» + ប្រយោជន៍ «ដំណើរដែលគួរប្រកប, អ្វីៗ ដែលគេត្រូវការ ឬ គេប្រកបទៅកើតការ,

ផលដែលសម្រេចអំពីការប្រកប» បានដល់អ្វីៗដែលគេប្រកបទៅកើតការយ៉ាងសំខាន់ ឬ ដំណើរដែលគេប្រកបទៅហើយសម្រេចបានផលចម្រើនយ៉ាងសំខាន់ ។

ហិមៈ ( Neige n. f. ) (អ.ថ. ហិ-មៈ) ន.(សំ. ម. ហិម) ទឹកសន្សើម ។

អធិ. ហិមៈនេះបានដល់ទឹកសន្សើម គឺទឹកដែលអាកាសធាតុជាប់ទឹកឡើង ហើយធ្លាក់ចុះមកលើផែនពសុធាដូចជាទឹកដែលគេដាំពុះហើយចំហាយជាប់នៅនឹងគ្របឆ្នាំងដូច្នោះឯង ។

ហិរញ្ញបញ្ញត្តិ (Loi des finances) (អ.ថ. ហិ-រ៉ុញ-ញៈ ប័ញ-ញ៉ាត់) ន. (ម. ; សំ.ហិរណ្យប្រជ្ញប្តិ) បញ្ញត្តិអំពីការចាយប្រាក់, ច្បាប់ខាងឃ្លាំងប្រាក់ ។

អធិ. ហិរញ្ញបញ្ញត្តិនេះ< ហិរញ្ញ “ ប្រាក់ ឬ មាស, ប្រាក់មាស ឬ មាសប្រាក់,„ + បញ្ញត្តិ “ ច្បាប់, សេចក្តីហាមប្រាម, បំរាម, សេចក្តីដែលគេតែងតាំង, រៀបចំ...„

ធ្មានផលបំរាមស្ដីអំពីការចាយវាយប្រាក់ ឬ បញ្ញត្តិអំពីការរៀបចំប្រាក់សម្រាប់ចាយវាយរបស់ក្រសួងឃ្លាំងប្រាក់ ។

ហិរញ្ញវត្ថុ (Finance n.f.) (អ. ថ. ហិ-រុញ-វ័ត-ថុ) ន. (ម. ; សំ. ហិរណ្យវស្តុ) វត្ថុគឺប្រាក់ ឬមាស , របស់-សម្រាប់ចាយចំនួសប្រាក់ ឬ មាស ។

អធិ. ហិរញ្ញវត្ថុនេះ < ហិរញ្ញ «ប្រាក់ ឬ មាស , ប្រាក់មាស ឬ មាសប្រាក់ ; ទ្រព្យ» + វត្ថុ «របស់ជាទីតាំង , ទ្រព្យ, អំពាន់ , ហេតុ , ដើមហេតុ , លំនៅ , ទី ...» ធ្មានផលលំនៅសម្រាប់ដាក់ប្រាក់ ឬ មាស គឺសំដៅយកឃ្លាំងប្រាក់ ១.ព. ក្រសួងហិរញ្ញវត្ថុ (Ministère des Finances) ។

ហិរញ្ញាធិការ (Financier n.m.) (អ. ថ. ហិ-រុញ-ញា-) ន. (ម. ; សំ. ហិរណ្យាធិការិន៍) អ្នកត្រួតត្រាខាងប្រាក់សម្រាប់ចាយ , អ្នកកាន់កាប់ , ត្រួតត្រាខាងឃ្លាំងប្រាក់ ។

អធិ. ហិរញ្ញាធិការនេះ < ហិរញ្ញ «ប្រាក់ ឬ មាស , ប្រាក់

មាស ឬ មាសប្រាក់, ទ្រព្យ»+ អធិការី «ជនអ្នកត្រួតត្រា, ជនអ្នកគ្រប់គ្រង, ជនអ្នកបង្គាប់ការ, ជនអ្នកបញ្ជាការ...» បានដល់ជនអ្នកគ្រប់គ្រងកិច្ចការខាងហិរញ្ញវត្ថុ ឬ ជនអ្នកត្រួតត្រាខាងឃាំងប្រាក់ គឺខាងហាងអ្នកត្រួតត្រាឃ្លាំង ។

ហេតុ (Motif n.m.) (អ·ច· ហែត) ន· (សំ·ម·) ការ ឬដំណើរដែលប្រព្រឹត្តទៅ ។

អធិ. ហេតុនេះ បានដល់ដំណើរដែលប្រព្រឹត្តទៅ ឬ ការណ៍, ដំណើរ, រឿង, ទំនង, ដើមទង, ទងគន្លង, ដើមចម, ផ្លូវ, ផ្លូវសេចក្ដី, រឿង, បំណង ។

| |
|---|
| អក្ខរិពន្ធ<br>« ឃុន-គិមប៊ូរ » |

មានតទៅភាគ ៥ ទៀត

កម្ពុជរដ្ឋ

លេខ១៤៣វិថីព្រះបាទត្រសក់ផ្អែមបន្ត
ភ្នំពេញ

តម្លៃ ២២ ៛០០